00700673

E51/7/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា**
**ស្ដីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 05 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

E51/7/1

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | **មេធាវីការពារក្តីជនជាប់ចោទ:** |
| ពេជ អង្គ | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- អនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាដាក់ជូនសារណានេះ ដែលលើកឡើងពី "មូលដ្ឋាននៃអំណះអំណាងរបស់ខ្លួនដែលថា បទឧក្រិដ្ឋជាតិមិនត្រូវបានរារាំងដោយអាជ្ញាយុកាលទេ ពាក់ព័ន្ធទៅនឹងជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿងលេខ០០២"[1]។

២- នៅក្នុងសេចក្តីសម្រេចនានារបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង បញ្ហាដែលត្រូវកំណត់លើរឿងនេះ គឺថាតើអាជ្ញាយុកាលបានផុតកំណត់ហើយឬនៅមុនពេលដែលរដ្ឋសភាជាតិកម្ពុជាបានពន្យារអាជ្ញាយុកាលពី១០ឆ្នាំ ទៅ៣០ឆ្នាំ នៅក្នុងឆ្នាំ២០០១[2]។ អង្គបុរេជំនុំជម្រះ និង ចៅក្រមកម្ពុជានានានៃអង្គជំនុំជម្រះសាលាដំបូងបានសម្រេចសេចក្តីថា ដោយសារតែពុំមានប្រព័ន្ធយុត្តិធម៌មួយដែលដំណើរការបាន និងដោយសារសង្គ្រាមស៊ីវិលជាបន្តបន្ទាប់ប្រឆាំងនឹងពួកខ្មែរក្រហមនោះ អាជ្ញាយុកាលត្រូវបានព្យួរយ៉ាងហោចណាស់រហូតដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ (កាលបរិច្ឆេទដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង តាមរយៈការប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញរបស់ខ្លួន) ហេតុដូច្នេះ មិនផុតអាជ្ញាយុកាលទេចាប់ពីឆ្នាំ២០០១[3]។ ចៅក្រមអន្តរជាតិ២រូប នៃអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សំណុំរឿងលេខ០០១នៅចំពោះមុខពួកគេឃើញមានភស្តុតាងមិនគ្រប់គ្រាន់ ដើម្បីផ្តល់សក្ខីកម្មអំពីអសមត្ថភាពជាក់ច្បាស់នៃប្រព័ន្ធច្បាប់កម្ពុជាពីឆ្នាំ១៩៧៩-១៩៩៣ ហេតុដូច្នេះ សន្និដ្ឋានថា អាជ្ញាយុកាលបានផុតកំណត់រួចជាស្រេចមុនពេលមានការពន្យារនៅឆ្នាំ២០០១[4]។

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ *សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ,* ថ្ងៃទី៥ មេសា ២០១១, E51/7 ត្រង់លេខ ERN 00658621 ។

[2] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អវតក"), មាត្រា៣ ។ ច្បាប់ អវតក ត្រូវបានរដ្ឋសភាជាតិអនុម័តជាដំបូងនៅថ្ងៃទី២ មករា ២០០១, ព្រឹទ្ធសភាបានពិនិត្យអនុម័តនៅថ្ងៃទី១៥ មករា ២០០១, ហើយបន្ទាប់ពីការអនុម័ត និងពិនិត្យអនុម័តលើវិសោធនកម្មមាត្រា៣ ព្រះមហាក្សត្របានឡាយព្រះហស្តលេខា និងបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ សីហា ២០០១ ។ ក្រោយមក អាជ្ញាយុកាលត្រូវបានពន្យារដល់ ៤០ឆ្នាំ តាមរយៈការធ្វើវិសោធនកម្មមួយលើមាត្រា៣ នៃច្បាប់ អវតក ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦) ។

[3] អង្គបុរេជំនុំជម្រះ, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១១ មេសា ២០១១, D427/1/30, កថាខណ្ឌទី ២៨៥-២៨៧ ("សាលដីការបស់ អបជ លើករណីរបស់ អៀង សារី")។ អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, ថ្ងៃទី២៦ កក្កដា ២០១០, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/ អជសដ, E187, កថាខណ្ឌទី ១៩-២៥ ("សេចក្តីសម្រេចរបស់ អជសដ ស្តីពីអាជ្ញាយុកាល") ។

[4] សេចក្តីសម្រេចរបស់ អជសដ ស្តីពីអាជ្ញាយុកាល, កថាខណ្ឌទី ៣១-៣៥ ។

៣- ដោយសារតែវាជាបញ្ហាដែលត្រូវកំណត់ នៅក្នុងសេចក្តីសម្រេចនានាពីមុនរបស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញានឹងលើកឡើងនៅក្នុងសារណានេះ ពីអង្គហេតុ និងអង្គច្បាប់នានាដែលគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា អាជ្ញាយុកាលចំពោះបទល្មើសជាតិមិនផុតកំណត់ទេ នៅមុនពេលមានការពន្យារពេលកំណត់នៅឆ្នាំ២០០១។ ដោយមានមូលដ្ឋាននៅលើគោលការណ៍ស្តីពី *contra non valentem agere nulla currit praescriptio* ("prescription does not run against he who cannot act") ("អាជ្ញាយុកាលមិនប្រើប្រឆាំងទៅនឹងជនដែលមិនបានប្រព្រឹត្តទេ") រដ្ឋទាំងឡាយបានយល់ឃើញជាសាកលថា លក្ខខណ្ឌនានាដែលធ្វើឱ្យវាស្ទើរតែមិនអាចប្រតិបត្តិបានក្នុងចំណាត់ការតាមផ្លូវច្បាប់, ដូចជាស្ថានភាពដែលមានសង្គ្រាមជាដើម, បានបង្អាក់ដំណើរការតុលាការ ឬការប្រព្រឹត្តិរបស់ចុងចោទ, បានផ្អាកអាជ្ញាយុកាល។ នៅក្នុងករណីនេះ ភ័ស្តុតាងត្រូវបង្ហាញថា៖ (ក)មិនមានប្រព័ន្ធតុលាការមួយដំណើរការបានទេនៅកម្ពុជាដែលអាចដឹកនាំធ្វើការកាត់សេចក្តី លើជនជាប់ចោទឱ្យបានត្រឹមត្រូវទេ យ៉ាងហោចណាស់រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០, (ខ)សង្គ្រាមស៊ីវិលជាបន្តបន្ទាប់បានធ្វើឱ្យស្ទើរតែមិនអាចកាត់សេចក្តីលើជនជាប់ចោទបាន រហូតទាល់តែពួកគេបានចុះចូលជាមួយនឹងរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ១៩៩៦ និង១៩៩៨, និង(គ)ជនចាប់ចោទត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះលក្ខខណ្ឌនានា ដែលបានរារាំងដល់ការកាត់សេចក្តីលើពួកគេក្នុងអំឡុងរយៈពេលនោះ។

៤- ទោះបីជាសេចក្តីសន្និដ្ឋាននេះ នឹងផ្តោតទាំងស្រុងទៅលើបញ្ហានានាខាងលើនេះក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនលះបង់សិទ្ធិធ្វើសេចក្តីសំអាងបន្ថែម ដែលពួកខ្លួនធ្លាប់បានធ្វើពីមុនរួចមកហើយនោះដែលមានលក្ខណៈស្របតាមបញ្ហានេះទេ[5] ដោយរួមទាំងអំណះអំណាងនានារបស់ខ្លួន៖ ទី១) ដូចដែលតុលាការធម្មនុញ្ញនៃប្រទេសឆេកបានសម្រេចសេចក្តីថា ការប្រែប្រួលមានប្រតិសកម្មនៅក្នុងអាជ្ញាយុកាល គឺជាសកម្មភាពនៃដំណើរការនីតិវិធីមួយដែលមិនរំលោភលើគោលការណ៍ស្តីពីនីត្យានុកូលភាពទេ[6], និងទី២) សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញប្រទេសកម្ពុជាលើមាត្រា៣ នៃច្បាប់ អវតក

[5] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៩ វិច្ឆិកា ២០១០, D427/3/6, កថាខណ្ឌទី ៨៣-១៣០ ("ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍") ។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងអញ្ញត្រកម្មរបស់មេធាវីការពារក្តី អនុលោមតាមវិធាន៨៩, ថ្ងៃទី២១ មីនា ២០១១, E51/5/3/1, កថាខណ្ឌទី ១២-១៧ ។

[6] តុលាការធម្មនុញ្ញនៃប្រទេសឆេក, សេចក្តីសម្រេចលើច្បាប់ឆ្នាំ១៩៩៣ ស្តីពីអនីត្យានុកូលភាពនៃរបបកុម្មុយនីស្ត, ថ្ងៃទី២១ ធ្នូ ១៩៩៣, បោះពុម្ពឡើងវិញនៅក្នុង *យុត្តិធម៌អន្តរកាល៖ ដោយយករបបមុនមកពិចារណាតើប្រជាធិបតេយ្យកើតឡើងយ៉ាងដូចម្តេច,* D288/6.9/7.12, ត្រង់លេខ ERN 00335995-96 [ដោយបានបញ្ជាក់ពីសុពលភាពនៃច្បាប់ឆ្នាំ១៩៩៣ ដែលចែងថា អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មពីអតីតមិនរាប់បញ្ចូលនូវរយៈពេលពីថ្ងៃទី២៥ កុម្ភៈ ១៩៤៨ ដល់ ថ្ងៃទី២៥ ធ្នូ ១៩៨៩ ទេ] ។

ថា មិនបានរំលោភលើសិទ្ធិណាមួយដែលមាននៅក្នុងរដ្ឋធម្មនុញ្ញទេ គឺវាមានលក្ខណៈចុងក្រោយ និងភ្ជាប់កាតព្វកិច្ច និងមិនអាចត្រូវបានពិនិត្យសាឡើងវិញដោយអង្គជំនុំជម្រះនេះទេ ពីព្រោះចៅក្រម និងព្រះរាជអាជ្ញាគ្មានសិទ្ធិបកស្រាយច្បាប់ដែលសភាជាតិបានអនុម័ត[7]។

## II. សេចក្តីថ្លែងពីអង្គហេតុ

### ក. ប្រវត្តិប្រព័ន្ធច្បាប់កម្ពុជា

*របបកម្ពុជាប្រជាធិបតេយ្យ៖ ខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩*

៥- ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ អត្ថិភាពនៃតុលាការកម្ពុជា (ក៏ដូចជាផ្នែកផ្សេងៗទៀតនៃរដ្ឋាភិបាលមុន និងរចនាសម្ព័ន្ធសង្គម) ត្រូវរំលាយ ហើយបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកចៅក្រម និងមេធាវីការពារក្តីថាជាគោលដៅត្រូវសម្លាប់ចោល ព្រោះជាសត្រូវវណ្ណៈ ឬជាមន្ត្រីនៃរបបមុន[8]។ រីឯមាត្រា៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ ចែងថាតុលាការ "ជាតុលាការរបស់ប្រជាជន" ហើយថា "តុលាការគ្រប់ជាន់ថ្នាក់" ត្រូវសភាតំណាងប្រជាជន (ដែលមាន នួន ជា ជាប្រធាន) ជ្រើសរើស និងតែងតាំង[9] ដែលតាមពិតទៅ មិនមានតុលាការណាមួយត្រូវបានបង្កើតឡើងនោះទេ[10]។ ក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈច្បាប់ចំនួនពី៤០០ ទៅ៦០០នាក់ ដែលបានរស់នៅក្នុងប្រទេសកម្ពុជា នៅមុនឆ្នាំ១៩៧៥ គឺមានតែមួយចំនួនតូចប៉ុណ្ណោះ (រវាងពី៦ ទៅ១២នាក់) ដែល

---

[7] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១០០-១០២ ។

[8] មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានច្បាប់កម្ពុជា ("CLRDC"), *ប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា,* ខែមករា ឆ្នាំ១៩៩៨, D288/6.9/8.18, ត្រង់លេខ ERN 00336370-71 ។

[9] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី៦ មករា ១៩៧៦, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ឧបសម្ព័ន្ធ គ.៩.២ ត្រង់លេខ ERN 00184836 ។ កំណត់ហេតុរបស់សភាតំណាងប្រជាជនកម្ពុជានៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី១១-១៣ មេសា ១៩៧៦, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ឧបសម្ព័ន្ធ គ.១៣.១៣ ត្រង់លេខ ERN 00184073 ។ សេចក្តីសម្រេចរបស់គណៈមជ្ឈិម បកក, ថ្ងៃទី៣០ មីនា ១៩៧៦, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ឧបសម្ព័ន្ធ គ.៦.៣ ត្រង់លេខ ERN 00182813 ។

[10] កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច, D86/21 ត្រង់លេខ ERN 00177588, D86/27 ត្រង់លេខ ERN 00204356 [ដោយបានសារភាពថាមនុស្សដែលបក្សបានចាប់ខ្លួន ឃាត់ខ្លួន និងធ្វើឃាតនៅមន្ទីរស-២១ ដោយ "អត់ជំនុំជម្រះ" ឬ "អត្ថិភាពនៃ តុលាការ និងការធានាពីដំណើរការនីតិវិធី"] ។ កំណត់ហេតុនៃការស្តាប់ចម្លើយ មាស សឿន, D232/88 ត្រង់លេខ ERN 00425890 ។ កំណត់ហេតុនៃការស្តាប់ចម្លើយ នង សុផង់ (Norng Sophâng), D200/9 ត្រង់លេខ ERN 00483969 ។

បាននៅរស់រានមានជីវិត និងនៅសល់នៅក្នុងប្រទេស ខណៈដែលរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ ហើយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាប់ផ្តើមនៅខែមករា ឆ្នាំ១៩៧៩[11]។

### *ឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨១*

៦- ប្រព័ន្ធតុលាការដែលត្រូវបានបង្កើតឡើងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយដែលបានបន្តនៅមានអានុភាពរហូតដល់មានដំណើរការ នៃការបង្កើតតុលាការស្របច្បាប់ជាថ្មីឡើងវិញ ក្នុងឆ្នាំ១៩៩២ និងឆ្នាំ១៩៩៣ មានមូលដ្ឋាននៅលើគំរូតាមសង្គមនិយមសូវៀត ដែលធ្លាប់ត្រូវបានអនុវត្តនៅប្រទេសវៀតណាម[12]។ នៅក្នុងរយៈកាលឆ្នាំ១៩៧៩ ដល់១៩៨១ ទាំងប្រព័ន្ធច្បាប់ស៊ីវិលបារាំង និងទាំងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានយកមកអនុវត្តឡើយ។ ផ្ទុយទៅវិញ ក្រមព្រហ្មទណ្ឌដែលយកមកអនុវត្ត គឺមាននៅក្នុងក្រឹត្យច្បាប់ឆ្នាំ១៩៨០ ដែលមានចំណងជើងថា "ច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្ត" ដែលត្រូវបានព្រាងឡើងដោយអ្នកដែលមិនមែនជាអ្នកច្បាប់មួយរូប ក្នុងរយៈពេលចំនួនមួយសប្តាហ៍ និងមាន១២មាត្រាខ្លីៗ ដែលបានផ្តោតជាចម្បងទៅលើបទឧក្រិដ្ឋនយោបាយ ព្រមទាំងក្រឹត្យច្បាប់ឆ្នាំ១៩៨២ ដែលមានចំណងជើងថា "ច្បាប់ស្តីពីការរៀបចំតុលាការ និងអយ្យការ"[13]។ បទឧក្រិដ្ឋចម្បង នៅក្នុងរយៈកាលនោះគឺ "ក្បត់បដិវត្ត" ដែលត្រូវបានផ្តល់និយមន័យ ថាជា "តវ៉ាប្រឆាំងនឹងប្រទេសជាតិ, ធ្វើសកម្មភាពប្រឆាំងនឹងឯករាជ្យភាព និងអធិបតេយ្យភាព ឯករាជរបស់ប្រទេសជាតិ, ឬ ធ្វើឱ្យប៉ះពាល់ដល់រដ្ឋអំណាចបដិវត្ត និងកិច្ចការពារប្រទេសជាតិ"[14]។ កិច្ចប្រឹងប្រែងនានារបស់លោក អ៊ុក ប៊ុនឈឿន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងការ

---

[11] Kathryn Neilson, *ពួកគេសម្លាប់ពួកអ្នកច្បាប់ទាំងអស់: ការកសាងប្រព័ន្ធច្បាប់ឡើងវិញនៅកម្ពុជា, ខែតុលា ១៩៩៦,* D288/6.9/5.26 ត្រង់លេខ ERN 00333019 (បន្ទាប់ទៅនេះហៅថា "*Neilson*") ។ CLRDC, *ប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា,* D288/6.9/8.18 ត្រង់លេខ ERN 00336371 ។ Dolores A. Donovan, *កម្ពុជា: ការកសាងប្រព័ន្ធច្បាប់មួយពីបាតដៃទទេ, ទស្សនាវដ្តី* The International Lawyer, ក្បាលទី ២៧, លេខ ២, ឆ្នាំ១៩៩៣, ទំព័រទី ៤៤៥ (បន្ទាប់ទៅនេះហៅថា "*Donovan*") ។

[12] Basil Fernando, *ប្រព័ន្ធកាត់សេចក្តីនៅក្រោមគំរូខ្មែរ-វៀតណាម (១៩៨១-១៩៩៣),* D382.1.22 ត្រង់លេខERN 00532914 (បន្ទាប់ទៅនេះហៅថា "*Fernando*") ។ *Donovan*, ទំព័រទី ៤៤៦ ។ Suzannah Linton, *ការដាក់អង្គជំនុំជម្រះវិសាមញ្ញរបស់ប្រទេសកម្ពុជាឱ្យទៅជាបរិបទ,* ឆ្នាំ២០០៧, សៀវភៅច្បាប់អន្តរជាតិប្រចាំឆ្នាំនៅសាំងហ្គាពួរ, ទំព័រទី ១៩៩ (បន្ទាប់ទៅនេះហៅថា "*Linton*") ។

[13] ក្រឹត្យច្បាប់លេខ២ ស្តីពីការផ្តន្ទាទោសចំពោះការក្បត់បដិវត្ត និងការផ្តន្ទាទោសផ្សេងៗចំពោះអំពើក្បត់ដទៃទៀត, ថ្ងៃទី១៥ មេសា ១៩៨០, D288/6.9/9.4 ("ក្រឹត្យច្បាប់លេខ២") ។ *Donovan*, ទំព័រទី ៤៤៨ ។ Evan Gottesman, *កម្ពុជាក្រោយ សម័យខ្មែរក្រហម: ខាងក្នុងនយោបាយកសាងជាតិ* (បន្ទាប់ទៅនេះហៅថា "*Gottesman*"), D382.1.20 ត្រង់លេខ ERN 00532910 (កថាខណ្ឌ ២៤០-២៤១) ។

[14] ក្រឹត្យច្បាប់លេខ២, D288/6.9/9.4 ត្រង់លេខ ERN 00336570 (មាត្រា៣) ។

ព្រាងច្បាប់សារធាតុមួយស្តីពីក្រមព្រហ្មទណ្ឌ ដែលនៅក្នុងនោះមានជាបទឧក្រិដ្ឋ និងបទមជ្ឈិម មិនបានទទួលជោគជ័យទេ[15]។

៧- តុលាការលើកទី១ដែលត្រូវបានបង្កើតឡើង ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា(PRK) គឺតុលាការប្រជាជនបដិវត្តន៍កម្ពុជា ដែលត្រូវបានគេប្រើ "សវនាការគ្រាន់តែជាឆាកសម្តែង" សំរាប់ជំនុំជម្រះក្តីលើ ប៉ុល ពត និង អៀង សារី នាខែសីហា ឆ្នាំ១៩៧៩[16]។ សវនាការនេះមានរយៈពេល៥ថ្ងៃ ហើយប្រធានតុលាការនេះ បានប្រកាសជាសាធារណៈអំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅមុនពេលដែលសវនាការជំនុំជម្រះក្តីបានចាប់ផ្តើម[17]។ តុលាការនេះ គឺជាតុលាការ "ដែលបិទផ្លូវតវ៉ា" ដែលជនជាប់ចោទតែម្នាក់ប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត ហើយនៅមាន "សិទ្ធិស្នើសុំការត្រាប្រណីទោសពីក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា"[18]។

៨- តុលាការផ្សេងៗទៀតដែលមានអត្ថិភាពនៅក្នុងអម្លុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ ត្រូវបានគេជឿថាស្រដៀងគ្នានឹងតុលាការប្រជាជនបដិវត្តន៍ដែរ[19]។ ចៅក្រមភាគច្រើន គឺជាអតីតគ្រូបង្រៀន ទាហាន និងជាជនផ្សេងទៀតដែលគ្មាន ឬក៏មានការបណ្តុះបណ្តាខាងផ្នែកច្បាប់តិចតួច[20]។ អនុលោមតាមច្បាប់មួយស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៨៩ ដែលបានអនុម័តបន្ទាប់ពីការបង្កើតរដ្ឋកម្ពុជា ករណីរឿងផ្សេងៗត្រូវបានសម្រេចដោយក្រុមប្រឹក្សាមួយដែលមានចៅក្រមមួយរូប និង"អ្នកវាយតម្លៃរបស់ប្រជាជន" ចំនួន២រូប[21]។ ដោយសារគ្មានមេធាវីឯកជននោះ អ្នកការពារក្តីត្រូវបាន ជ្រើសរើសមកពីក្រុម "អ្នកការពារក្តីសំរាប់សង្គម"មួយ ដែលបុគ្គលិកមិនមែនជាអ្នកច្បាប់ត្រូវបានគេជួលឱ្យមកបំរើការងារនៅក្នុងតុលាការនីមួយៗ ថ្វីបើជនជាប់ចោទណាម្នាក់បានទទួលតែតំណាងបែបនេះ

---

[15] *Gottesman*, D382.1.20 ត្រង់លេខ ERN 00532912 (ទំព័រទី ២៤៤) ។

[16] ក្រិត្យច្បាប់លេខ ១ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍កម្ពុជានៅទីក្រុងភ្នំពេញដើម្បីជំនុំជម្រះក្តីលើបន ប៉ុល ពត និងអៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី១៥ កក្កដា ១៩៧៩, ឯកសារលេខ D288/6.9/9.3 ("ក្រិត្យលេខ ១")។ សេចក្តីសង្ខេបរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជា , ខែសីហា ឆ្នាំ១៩៧៩, ឯកសារលេខ D313/1.2/2.401 ។

[17] *Linton*, កថាខណ្ឌទី២០៨-២០៩។

[18] ក្រិត្យច្បាប់លេខ ១, ឯកសារលេខ D288/6.9/9.3 ត្រង់លេខ ERN 00336568 (មាត្រា 7) ។

[19] *Fernando*, ឯកសារលេខ D382.1.22 ត្រង់លេខ ERN 00532914-15 (ដែលលើកឡើងថា សាលក្រមទាំងឡាយត្រូវបានកំណត់សម្រេចមុនពេលសវនាការ ក្រោយពីបានស្វែងរកយោបល់ណែនាំពីចៅហ្វាយខេត្ត ឬ ពីក្រសួងយុត្តិធម៌។

[20] *Gottesman*, ឯកសារលេខ D382.1.20 ត្រង់លេខ ERN 00532912 (ទំព័រ. 244)។ CLRDC, *អំពីប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជា*, ខែមករា ឆ្នាំ១៩៩៨, ទំព័រ.១៥០។

[21] *Donovan*, ទំព័រ ៤៥១។

បើសិនជាការផ្តន្ទាទោសដ៏មានសក្តានុពលរបស់ខ្លួនមានរយៈពេលលើសពី៥ឆ្នាំ[22]។ (ដូចដែលបានលើកឡើងពិភាក្សាខាងក្រោមនេះ គឺរហូតទល់នឹងឆ្នាំ១៩៩៥ ដែលគណៈមេធាវីមួយត្រូវបានបង្កើតឡើង ទើបមានមេធាវីការពារក្តីដែលមានសមត្ថភាពដែរអាចឲ្យរកបានសម្រាប់តំណាង)។

៩- នៅក្នុងអម្លុងពេលចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ សាលាឧទ្ធរណ៍ក៏គ្មាន ហើយសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក៏គ្មានដែរ[23]។ នៅពេលដែលតុលាការកំពូលត្រូវបានបង្កើតឡើងដោយក្រិត្យច្បាប់មួយ នៅឆ្នាំ១៩៨៥ ហើយដែលបានដំណើរការត្រឹមឆ្នាំ១៩៨៧នោះ តុលាការនេះមានសិទ្ធិអំណាចដែលមានកម្រិត ហើយមិនមានតួនាទីខាងតុលាការប្រកបដោយប្រសិទ្ធភាពនោះទេ នៅមុនឆ្នាំ១៩៩៤[24]។ តាមការអនុវត្តជាក់ស្តែង ក្រសួងយុត្តិធម៌ គឺជាអ្នកដែលពិនិត្យមើលឡើងវិញលើគ្រប់សាលក្រមទាំងអស់ អំពីភាពត្រឹមត្រូវទាំងអង្គហេតុ និងទាំងអង្គច្បាប់[25]។

១០- ចាប់តាំងពីខែមករា ឆ្នាំ១៩៧៩ រហូតដល់ខែកញ្ញា ឆ្នាំ១៩៩២ មិនឃើញមានច្បាប់ជាធរមានណាមួយដែលតម្រូវឲ្យករណីរឿងព្រហ្មទណ្ឌនានាត្រូវបានលើកឡើងនៅក្នុងអម្លុងពេលយ៉ាងយូរ១០ឆ្នាំឡើយ។ ហើយក៏មិនមានច្បាប់លំអិតណាមួយ ដែលអនុញ្ញាតឲ្យធ្វើការកាត់សេចក្តីប្រកបដោយប្រសិទ្ធិភាពលើបទល្មើស អំពើមនុស្សឃាត ការធ្វើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញខាងសាសនា[26]។

---

[22] *Donovan*, កថាខណ្ឌទី ៤៥០-៤៥២។

[23] *Donovan*, ទំព័រ ៤៥១។ *Gottesman*, ឯកសារលេខ D382.1.20 ត្រង់លេខ ERN 00532912 (ទំព័រ. ២៤៥)។ *Fernando*, ឯកសារលេខ D382.1.22 ត្រង់លេខ ERN 00532915។ *Neilson*, ឯកសារលេខ D288/6.9/5.26 ត្រង់លេខ ERN 00333019។

[24] ច្បាប់ស្តីពីការរៀបចំនៃតុលាការកំពូលប្រជាជនបដិវត្តន៍ និងមហាអយ្យការអមតុលាការកំពូល, ក្រិត្យច្បាប់លេខ ២៨ ក្រ, ចុះថ្ងៃទី៣១ កក្កដា ១៩៨៥។ ច្បាប់ស្តីពីការរៀបចំនៃតុលាការកំពូលប្រជាជនបដិវត្តន៍ និងមហាអយ្យការអមតុលាការកំពូល, ក្រិត្យច្បាប់លេខ ៣៤ ក្រ, ចុះថ្ងៃទី២៦ សីហា ១៩៨៧ *Donovan*, កថាខណ្ឌទី ៤៤៨-៤៥១ [ដែលកត់សំគាល់ថា "សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល គឺគ្មានអត្ថិភាពទេ"]។ គំរោងអ្នកការពារក្តីកម្ពុជា, *មគ្គុទេសក៍ណែនាំដែលជាប្រភពធនធានអំពីច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា*, ឯកសារលេខ D288/6.9/8.16 ត្រង់លេខ ERN 00336395 (§2.17)។ *Neilson*, ឯកសារលេខ D288/6.9/5.26 ត្រង់លេខ ERN 00333021 [ដែលយោងទៅលើរបាយការណ៍ឆ្នាំ១៩៨៩ដោយតុលាការកំពូលថាខ្លួន "មិនមានសមត្ថកិច្ចដោះស្រាយលើរឿងក្តីដោយខ្លួនឯងផ្ទាល់នោះទេ"]។

[25] *Gottesman*, ឯកសារលេខ D382.1.20 ត្រង់លេខ ERN 00532912 (ទំព័រ. ២៤៥)។ *Linton*, ទំព័រទី២០០។ គំរោងអ្នកការពារក្តីកម្ពុជា, *មគ្គុទេសក៍ណែនាំដែលជាប្រភពធនធានអំពីច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា*, ឯកសារលេខ D288/6.9/8.16 ត្រង់លេខ ERN 00336395 (§2.17)។

[26] មានតែច្បាប់ដ៏មានសក្តានុពលដែលគ្របដណ្តប់លើបទល្មើសអំពើឃាតកម្ម ឬការធ្វើទារុណកម្មដែលមានចែងនៅក្នុងមាត្រា៧នៃក្រិត្យច្បាប់ខែមេសា ឆ្នាំ១៩៨០តែប៉ុណ្ណោះ ដែលគ្រាន់តែចែងថា: (ក) "[]ជនណាដែលប្រព្រឹត្តបទមនុស្សឃាដទោះក្នុងទម្រង់ណាមួយក៏ដោយត្រូវផ្តន្ទាទោសពី១០ ទៅ២០ឆ្នាំ " ទោះបីជាអាចនឹងត្រូវបានអនុញ្ញាតឲ្យលើកលែងទោសក៏ដោយ "[] បើសិនជាយល់ឃើញថាអំពើល្មើសនោះមិនមានលក្ខណៈធ្ងន់ធ្ងរ"។ (ខ) "[]ជនណាដែលបង្ករបួសស្នាមដោយចេតនាដល់ជនណាម្នាក់ដែលមានតំណែងដែលត្រូវបានចាត់ទុកថារសើប

នៅពេលដែលអតីតកម្មាភិបាលខ្មែរក្រហមត្រូវបានចាប់ខ្លួន ដោយសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក្នុងអំឡុងពេលនោះ គឺហាក់ដូចជាពួកគេគ្រាន់តែត្រូវបានដាក់ឲ្យជាប់ឃុំឃាំងនៅក្នុងពន្ធនាគារដោយគ្មានតុលាការណាមួយជំនុំជម្រះក្តីតែប៉ុណ្ណោះ[27]។

*ក្រោយឆ្នាំ១៩៩១*

១១- ដំណើរការក្នុងការកសាងឡើងវិញនូវប្រព័ន្ធតុលាការ ដែលត្រឹមត្រូវតាមច្បាប់នៅក្នុងប្រទេសកម្ពុជា ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩២ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស[28] និងក្នុងអំឡុងពេលដែលប្រទេសត្រូវបានតាមឃ្លាំមើល និងគ្រប់គ្រងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(UNTAC)។ មានការវិភាគមួយអំពីសភាពការណ៍ដែលបានបោះផ្សាយនៅក្នុងឆ្នាំ១៩៩៣ដែលមានចំណងជើងថា ៖ *ប្រទេសកម្ពុជា៖ ការកសាងប្រព័ន្ធច្បាប់មួយពីបាតដៃទទេ* ដែលបានរៀបរាប់អំពីបញ្ហាដែលត្រូវប្រឈមដូចខាងក្រោមនេះ៖

> “ប្រទេសកម្ពុជា ឥឡូវនេះមានច្បាប់ផ្សេងៗ ប៉ុន្តែច្បាប់ទាំងនោះមានតិចនិងស្ថិតនៅចន្លោះកណ្តាលដែលឃ្លាតឆ្ងាយពីគ្នា។ ប្រទេសនេះបានបង្កើតតុលាការនានា ប៉ុន្តែតុលាការទាំងនោះភាគច្រើនស្ទើរតែគ្មានដំណើរការ។ ដូចគ្នានេះដែរ មនុស្សជាច្រើនត្រូវបានគេតែងតាំងជាចៅក្រម និងរដ្ឋអាជ្ញា ប៉ុន្តែមានតែមួយចំនួនតូចប៉ុណ្ណោះដែលមានការសិក្សាអប់រំខាងផ្នែកច្បាប់។ មួយ គឺដោយសារសភាពការណ៍កាន់តែចុះដុនដាបទៅៗ។ ពីព្រោះ មានការហោចទៅៗ ដោយសារការស្លាប់ចំនួនអ្នកដែលមានការហ្វឹកហ្វឺនផ្នែកច្បាប់ពេញលេញជាអាជីពដែលមាន នៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះ គឺបានថយចំនួនចុះមកនៅតែប្រាំនាក់ប៉ុណ្ណោះ។ លើសពីនេះទៅទៀត កម្ពុជាគ្មានមេធាវីឯកជននោះទេ[29]។

១២- កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ច្បាប់មួយដែលតាក់តែងឡើងដោយតំណាង UNTAC ដែលមានចំណងជើងថា បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់ អនុវត្តនៅក្នុងប្រទេសក្នុងសម័យអន្តរកាល ត្រូវបានអនុម័តដែលបានចែងអំពីការបង្កើតឡើងនូវតុលាការ

---

ត្រូវផ្តន្ទាទោសចន្លោះពី៦ខែ ទៅដល់៥ឆ្នាំ”។ ក្រិត្យច្បាប់លេខ២, ឯកសារលេខ D288/6.9/9.4 ត្រង់លេខ ERN 00336572។ ក្នុងក្រិត្យនេះគ្មានចែងពីអាជ្ញាយុកាលឬ ទោសបញ្ញត្តិដែលទាក់ទងនឹងការធ្វើទុក្ខបុកម្នេញខាងសាសនាឡើយ។

[27] *Linton*, កថាខណ្ឌទី២១២-២១៣។ *Gottesman*, ឯកសារលេខ D382.1.20 ត្រង់លេខ ERN 00532913 (ទំព័រ. ២៤៦)។

[28] កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយនៃជម្លោះនៅកម្ពុជា, ចុះថ្ងៃទី២៣ តុលា ១៩៩១, D288/6.9/ 5.12 ។

[29] *Donovan*, កថាខណ្ឌទី ៤៤៥។

សម្រាប់ជំនុំជម្រះក្តី និងសាលាឧទ្ធរណ៍ នៅតាមខេត្តនីមួយៗរបស់ប្រទេស[30] និងបានពង្រីកសិទ្ធិអំណាច និងមុខងាររបស់តុលាការកំពូលឲ្យបានទូលំទូលាយ ដើម្បីរួមបញ្ចូលនូវ "ការពិនិត្យមើលឡើងវិញតាមផ្លូវតុលាការផ្នែកអង្គច្បាប់" និងពិនិត្យមើលឡើងវិញលើសាលដីកានានារបស់សាលាឧទ្ធរណ៍លើញត្តិស្នើសុំដែលធ្វើឡើងដោយអគ្គព្រះរាជអាជ្ញា ឬភាគីខាងទណ្ឌិត[31]។ ច្បាប់នេះបានធានាអំពីសិទ្ធិត្រូវមានមេធាវីការពារក្តី និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងតម្រូវឲ្យជនដែលត្រូវបានឃាត់ខ្លួនត្រូវតែបញ្ជូនមកចំពោះមុខចៅក្រមក្នុងរយៈពេល៤៨ម៉ោងយ៉ាងយូរ[32]។ ច្បាប់ UNTAC ឆ្នាំ១៩៩២ ក៏បានថែងយោងយ៉ាងច្បាស់ទៅលើការខ្វះខាតមួយចំនួននៅក្នុងប្រព័ន្ធច្បាប់ដែលមានស្រាប់។ ឧទាហរណ៍ដូចជា មាត្រា៧.២ បានថែងថា "ដោយចំនួនមេធាវីមានតិចតួចពេកនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរកាលនេះ ជនកម្ពុជាគ្រប់រូបដែលមានសញ្ញាប័ត្រមធ្យមសិក្សាអាចតំណាងឲ្យជនជាប់ចោទនៅក្នុងតុលាការបាន" ហើយ "ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារឲ្យធ្វើជាជំនួយផ្នែកច្បាប់បានទោះបីមានកម្រិតសិក្សាថ្នាក់ណាក៏ដោយ"។ ច្បាប់នេះក៏បានបង្កើតឲ្យមានផងដែរនូវអាជ្ញាយុកាលចំនួនបីឆ្នាំសម្រាប់បទមជ្ឈិម និងដប់ឆ្នាំសម្រាប់ "បទឧក្រិដ្ឋ" ផ្សេងទៀត ដូចជាបទ មនុស្សឃាដ បទរំលោភសេពសន្ថវៈ និងបទប្លន់[33]។

១៣- កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់លំអិតមួយស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះមាន៧ជំពូក និង២៣៨មាត្រាដែលត្រូវបានប្រកាសឲ្យប្រើដោយក្រុមប្រឹក្សារដ្ឋនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៣។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ បានដាក់បញ្ចូលឡើងវិញជាថ្មីនូវគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំង ដែលរួមមានទាំងការប្រើប្រាស់នូវចៅក្រមស៊ើបអង្កេត "ការស៊ើបអង្កេតបឋម" និង "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ" ដោយរដ្ឋអាជ្ញាបើកធ្វើកិច្ចស៊ើបអង្កេតបឋម និងចៅក្រមជំនុំជម្រះដែលដឹកនាំការសួរដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីនិងសាក្សីនានា[34]។ ច្បាប់នេះគឺសាលាឧទ្ធរណ៍ តែមួយគត់ដែលតាំងនៅក្នុងទីក្រុងភ្នំពេញ ដែលមានយុត្តាធិការនៅក្នុងទូទាំងប្រទេសកម្ពុជាទាំងមូលនិង ដែលបានទទួល

---

[30] បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០កញ្ញា ១៩៩២, មាត្រា៣និង៤ , (ដែលជាបន្តមកទៀតនៅក្នុងនេះហៅកាត់ថា"ច្បាប់ UNTAC ឆ្នាំ១៩៩២")។

[31] ច្បាប់ UNTAC ឆ្នាំ១៩៩២, មាត្រា៥។

[32] ច្បាប់ UNTAC ឆ្នាំ១៩៩២, មាត្រា៤.៤, ១០, និង១៣។

[33] ច្បាប់ UNTAC ឆ្នាំ១៩៩២, មាត្រា៣០។

[34] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣, មាត្រា៥៦, ៦០, ៦៨-៩៥, ១៣២-១៣៣។

ស្គាល់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ទៅសាលាក្តីនោះ[35]។ ជាបន្ទាប់មក សាលាឧទ្ធរណ៍នេះត្រូវបានបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ១៩៨៤[36]។ ច្បាប់ឆ្នាំ១៩៩៣ ក៏បានអនុម័តយកផងដែរនូវអាជ្ញាយុកាលដែលមានរយៈពេលបីឆ្នាំ សម្រាប់បទមជ្ឈិម និងដប់ឆ្នាំសម្រាប់បទឧក្រិដ្ឋ[37]។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ និងច្បាប់ UNTAC ឆ្នាំ១៩៩២ បង្កើតបានជាច្បាប់ដែលសម្រាប់ប្រតិបត្តិដែលតុលាការកម្ពុជាទាំងឡាយ បានអនុវត្តតាមរហូតមកដល់ពេលច្បាប់ទាំងនេះត្រូវបានចាត់ទុកជានិរាករណ៍ ហើយត្រូវបានដាក់ជំនួសដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧[38]។

១៤- ការខិតខំប្រឹងប្រែងដើម្បីបង្កើតឡើងនូវប្រព័ន្ធច្បាប់មួយដែលត្រឹមត្រូវតាមច្បាប់ នៅក្នុងប្រទេសកម្ពុជា ក៏បានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ផងដែរ ដែលក្នុងនោះមានការប្តេជ្ញាចិត្តមួយក្នុងការទទួលស្គាល់ និងគោរពតាមបទដ្ឋានសិទ្ធិមនុស្សទាំងឡាយដែលបានបង្កើតឡើងនៅក្នុងច្បាប់អន្តរជាតិ[39]។

១៥- កិច្ចប្រឹងប្រែងដ៏សំខាន់ ដើម្បីបង្កើតស្ថាប័ននៃអ្នកអាជីពច្បាប់ដ៏មានគុណវុឌ្ឍិមួយ ក៏បានកើតឡើងផងដែរនៅក្នុងអម្លុងពេលនេះ។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់របស់សភាជាតិ អនុម័តនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥[40]។ គណៈមេធាវីបានចាប់ផ្តើមបំពេញមុខងាររបស់ខ្លួននៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ នៅពេលដែលមេធាវីចំនួន៣៨រូប បានស្បថចូលកាន់តំណែងនៅចំពោះមុខសាលាឧទ្ធរណ៍[41]។ ត្រឹមខែកញ្ញា ឆ្នាំ១៩៩៦ ចំនួនមេធាវីក្នុងគណៈមេធាវីបានកើនឡើងរហូតដល់៥៤រូប[42]។ ក្នុងសរទរដូវឆ្នាំ១៩៩២ ស្ថាប័នរដ្ឋបាលសាធារណៈ

---

[35] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣, មាត្រា១៥៦, ១៦១។

[36] *Neilson*, ឯកសារលេខ D288/6.9/5.26 ត្រង់លេខ ERN 00333032។

[37] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣, មាត្រា១១៧។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, ចុះថ្ងៃទី១០ សីហា ២០០៧, មាត្រា៦១១។ *Fernando*, ឯកសារលេខ D382.1.22 ត្រង់លេខ ERN 00532917។

[39] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៣១-៥១, ៧៦, ១០៩-១១។

[40] CLRDC, *ប្រព័ន្ធច្បាប់របស់កម្ពុជា,* មករា ១៩៩៨, ទំព័រទី១៥០ ។

[41] CLRDC, *ប្រព័ន្ធច្បាប់របស់កម្ពុជា,* មករា ១៩៩៨, ទំព័រទី១៥១ ។

[42] CLRDC, *ប្រព័ន្ធច្បាប់របស់កម្ពុជា,* មករា ១៩៩៨, ទំព័រទី១៥១ ។

និងស្ថាប័នច្បាប់ បានចាប់ផ្តើមផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេល៥ឆ្នាំផ្នែកច្បាប់[43]។ ពីឆ្នាំ១៩៨៩ ដល់១៩៩២ ស្ថាប័ននេះធ្លាប់ផ្តល់កម្មវិធីបណ្តុះបណ្តាលច្បាប់រយៈពេល២ឆ្នាំ និងនៅមុនឆ្នាំ១៩៨៩ ស្ថាប័ននេះធ្លាប់ផ្តល់វគ្គបណ្តុះបណ្តាលច្បាប់តែរយៈពេលពីបី ឬប្រាំខែប៉ុណ្ណោះ[44]។

## ខ. ក្រោយសង្គ្រាមស៊ីវិលឆ្នាំ១៩៧៩

១៦- កម្ពុជានៅតែស្ថិតក្នុងស្ថានភាពនៃសង្គ្រាមស៊ីវិលដដែល ចាប់ពីពេលបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ក៏ឆ្លងកាត់ដល់ថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១[45] ដែរ។ ក្នុងអំឡុងពេលនេះ ជនជាប់ចោទនៅតែបន្តធ្វើមេដឹកនាំឱ្យកងកម្លាំងប្រឆាំងរបស់ខ្មែរក្រហម ដោយសកម្មមិនព្រមចុះចូលជាមួយនឹងដែនសមត្ថកិច្ចរបស់រដ្ឋាភិបាល PRK (ដែលក្រោយមកជា រដ្ឋកម្ពុជា) ដោយយកភ្នំនៅជិតព្រំដែនថៃ ធ្វើជាមូលដ្ឋាន និងការពារដោយកងទ័ពព្រៃចំនួនពី៣០,០០០ - ៥០,០០០នាក់[46]។ ឆ្លងដល់ឆ្នាំ១៩៩១ នេះដែរអង្គការសហប្រជាជាតិនៅតែបន្តទទួលស្គាល់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យថាជា ប្រធានរដ្ឋធម្មានុរូប ដែលមានសិទ្ធិធ្វើតំណាងឱ្យកម្ពុជានៅឯមហាសន្និបាតអង្គការសហប្រជាជាតិ[47]។ លក្ខខណ្ឌទាំងអស់នេះ បង្កើត

---

[43] *Donovan*, ទំព័រទី៤៥០ (n. 17) ។

[44] *Donovan*, ទំព័រទី៤៥០ (n. 17) ។

[45] សារទូរលេខរបស់ អៀង សារី ទៅ អ.ស.ប ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៩, D248/5.1.7, ERN S 00015001 (និយាយថា "ចាប់តាំងពីថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៩ មក កងទ័ពបដិវត្តន៍ និងប្រជាជនកម្ពុជា បានចាប់ផ្តើមការវាយបកជាច្រើនលើកច្រើនសារប្រឆាំងនឹងពួកឈ្លានពានវៀតណាម នៅគ្រប់ផ្នែកទាំងអស់នៃប្រទេស")។ សេចក្តីប្រកាសព័ត៌មានរបស់ខៀវ សំផន, ១ មករា ១៩៨៤, D56-Doc. 279 ត្រង់ERNS00036209; កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយនៃជម្លោះកម្ពុជា, ២៣ តុលា ១៩៩១, D288/6.9/5.12 ត្រង់ ERN 00330666 (មាត្រា៩នៃកិច្ចព្រមព្រៀងនេះចែងថា "បទឈប់បាញ់គ្នាត្រូវចូលជាធរមាននៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន") ។

[46] Nayan Chanda, *សត្រូវបងប្អូនឯង: សង្គ្រាមក្រោយសង្គ្រាម (Brother Enemy: The War After the War)*, D108/50/1.74, ត្រង់ ERN 00192169 ទំព័រ៣៩២ (និយាយថា កម្លាំងប្រយុទ្ធរបស់ខ្មែរក្រហមបានកើនឡើងពី 20,000 ដល់ 40,000 នាក់នៅត្រឹមបំណាច់ឆ្នាំ១៩៨០); Associated Press, *រដ្ឋាភិបាលចម្រុះកម្ពុជារាយការណ៍ថាទទួលបានជំនួយច្រើនទៀតពីប្រទេសចិន, សុំឱ្យ សរអា ជួយ*, ១០ ធ្នូ ១៩៨៥, D56-Doc.341 ត្រង់ ERN 00122417 [សេចក្តីថ្លែងការណ៍ដោយសម្តេច នរោត្តម សីហនុ ថា ខ្មែរក្រហមមាន "ទ័ពព្រៃច្រើនរហូតដល់ 50,000 នាក់"]; The Times, *ខ្មែរក្រហមនៅតែជាស្រមោលអន្ទោលតាមប្រាណនៅកម្ពុជា, ១៥ ធ្នូ ១៩៨៨*, D56-Doc.397 ត្រង់ ERN 00137580) ។

[47] *Linton*, ទំព័រទី 199; លេខាធិការដ្ឋាន អ.ស.ប, បញ្ជីឈ្មោះបណ្តោះអាសន្ននៃគណៈប្រតិភូចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣៩, ៩ វិច្ឆិកា ១៩៨៤, D56-Doc. 290; Associated Press, *រដ្ឋាភិបាលចម្រុះកម្ពុជារាយការណ៍ថាទទួលបានជំនួយច្រើនទៀតពីប្រទេសចិន, សុំឱ្យ សរអា ជួយ*, ១០ ធ្នូ ១៩៨៥, D56-Doc.341 ត្រង់ ERN 00122417។ ការណ៍នេះបានបន្តរហូតដល់មាន

បាននូវអលទ្ធភាពជារូបវ័ន្ត ខាងនយោបាយ និងការអនុវត្តសម្រាប់ជនជាប់ចោទមិនអាចឲ្យគេចាប់ខ្លួន និងនាំខ្លួនពួកគេមកវិនិច្ឆ័យទោសបាននៅក្នុងរយៈកាលនេះ។ វាមិនបានកើតឡើងទេ រហូតទាល់តែមកដល់ឆ្នាំ១៩៩៦ គឺនៅក្រោយពេលដែលកងកម្លាំងខ្មែរក្រហម បានធ្លាក់ចុះខ្សោយយ៉ាងខ្លាំងទើបរដ្ឋាភិបាល និងកងទ័ពកម្ពុជាមានលទ្ធភាពបង្កើតផែនការមួយ និងផ្តល់ការណែនាំសម្រាប់ការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់[48]។

១៧- ជនជាប់ចោទម្នាក់ៗមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំកងកម្លាំងប្រឆាំង ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល។ អៀង សារី បានចាប់ផ្តើមរយៈកាលមួយជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ និងជាតំណាងនៅ អ.ស.ប ជាអ្នកស្វែងរកមូលនិធិឧបត្ថម្ភចលនាតស៊ូខ្មែរក្រហម និងយូរៗទៅបានទទួលអំណាចលើការត្រួតត្រាតំបន់ និងកងកម្លាំងផ្ទាល់ខ្លួនរបស់គាត់(ប៉ៃលិន)[49]។ ខៀវ សំផន ជាមេដឹកនាំសាធារណៈនៃពួកប្រឆាំង និងជាអនុប្រធានទទួលបន្ទុកកិច្ចការបរទេសក្នុងជួររដ្ឋាភិបាល CGDK (រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ)[50] ។ អៀង ធីរិទ្ធ ជាប្រធានដឹកនាំ

---

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ ដែលនៅពេលនេះ ក្រុមប្រក្សាជាតិជាន់ខ្ពស់ ត្រូវបានទទួលស្គាល់ថាជា ស្ថាប័ន "តំណាងឲ្យកម្ពុជានៅក្រៅប្រទេស និងកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ" នៅក្នុងអំឡុងពេលនៃសម័យកាលអន្តរកាលនេះ ។ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយនៃជម្លោះកម្ពុជា, ២៣ តុលា ១៩៩១, D288/6.9/5.12 ត្រង់ ERN 00330666 (មាត្រា៥) ។

[48] AFP, *មេដឹកនាំកំពូលខ្មែរក្រហមចាកចេញនៅពេលកងទ័ពចូលកាន់តែកៀកតំបន់ក្បាលរឹងរបស់ទ័ពព្រៃ,* ១ មីនា ១៩៩៦, D56-Doc.423 ត្រង់ ERN 00107754; The Washington Post, *ព្រះអង្គម្ចាស់របស់កម្ពុជា, រួចផុតពីការនិរទេស,* ៣១ មីនា ១៩៩៨, D56-Doc. 472 ត្រង់ ERN 00131235-36; The Australian, *ខ្មែរក្រហមដែលចុះខ្សោយតស៊ូដើម្បីរំខានការបោះឆ្នោត,* ១ មេសា ១៩៩៨, D56-Doc. 474 ត្រង់ ERN 00131243 ។

[49] សារទូរលេខរបស់ អៀង សារី ទៅ អ.ស.ប ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៩, D248/5.1.7 ត្រង់ ERN S 00015001; Philip Short, *ប៉ុល ពត: ប្រវត្តិសាស្ត្រនៃសុបិន្តអាក្រក់*, D22211.15 ត្រង់ ERN 00396618-20, 00396653; Kyodo News Service, *អៀង សារី បញ្ចេញថ្លែងគាំទ្រ ស៊ីភីភី ក្នុងការបោះឆ្នោត,* ២៥ កក្កដា ១៩៩៨, D56-Doc. 475 ត្រង់ ERN 00118381; Craig Etcheson, *បន្ទាប់ពីវាលពិឃាដ*, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ឧបសម្ព័ន្ធ គ 4.14 ត្រង់ ERN 00078846; Nayan Chanda, *ការដួលរលំនៃពួកជនកុំម្មុយនិស្ត*... 

[50] New York Times, *កងទ័ពវៀតណាមបន្តជួបការតស៊ូដ៏ខ្លាំងក្លា,* ២ កុម្ភៈ ១៩៧៩, D56-Doc. 161 ត្រង់ ERN 00122171; Reuters, *ប្រជាជនកម្ពុជាត្រូវបានកៀបជាប់ដោយវៀតណាម, តាមជនជាតិថៃ,* ១៧ មេសា ១៩៧៩, D56-Doc. 163 ត្រង់ ERN 00122173; សេចក្តីប្រកាសព័ត៌មានរបស់ខៀវ សំផន, បេសកកម្មអចិន្ត្រៃយ៍របស់កម្ពុជាប្រជាធិបតេយ្យប្រចាំអង្គការសហប្រជាជាតិ, ១ មករា ១៩៨៤, D56-Doc. 279 ត្រង់ ERN S 00036209-11 (និយាយថា "អស់រយៈពេលប្រាំឆ្នាំនៃការតស៊ូ និងប្តូរផ្តាច់ប្រជាជនយើងកងទ័ពជាតិយើង និងកងទ័ពរំដោះរបស់យើងបានទទួលជ័យជំនះយ៉ាងត្រចះត្រចង់លើគ្រប់សមរភូមិទាំងអស់ប្រឆាំងនឹងពួកវៀតណាមឈ្លានពាន")។ BBC, *ខៀវ សំផន ធ្វើអត្ថាធិប្បាយស្តីពីអនាគតរបស់កម្ពុជា,* ១៩ មិថុនា ១៩៨៤, D56-Doc.283 ត្រង់

គណៈប្រតិភូសម្រាប់កិច្ចចចាររបស់ CGDK ហើយត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងកិច្ចការបរទេសនៃរដ្ឋាភិបាល CGDK[51]។ នួន ជា ធ្វើជាមេដឹកនាំសាធារណៈម្នាក់ផងដែរ ដោយបានអំណាចត្រួតត្រាលើតំបន់ចាប់ពីសំឡូតរហូតដល់កោះកុង និងជាអ្នកផ្តល់ការណែនាំដល់កងកម្លាំងទ័ពព្រៃ[52]។

១៨- ស្ថានភាពនៃសង្គ្រាមជាមួយកងកម្លាំងរបស់ខ្មែរក្រហម នៅតែបន្តនៅក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ និងការបង្កើតព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៩៩៣[53]។ វាមិនបានកើត

ERN 00122319; លេខាធិការដ្ឋាន អ.ស.ប, បញ្ជីឈ្មោះបណ្តោះអាសន្ននៃគណៈប្រតិភូចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣៩, ៩ វិច្ឆិកា ១៩៨៤, D56-Doc. 290 ត្រង់ ERN S 00022416; Associated Press, *ប្រធានខ្មែរក្រហមអះអាងពីការរុញច្រានវៀតណាម ឱ្យដកក្រោយ,* ២១ កុម្ភៈ ១៩៨៥, D56-Doc. 304 ត្រង់ ERN 00122370 (សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ថា កម្លាំងតស៊ូនឹងរក្សាបានកម្លាំងគ្រប់គ្រាន់ដើម្បី "អារកខ្មាំង"; សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ជូនចំពោះកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទីពីរនៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា, ២៨ សីហា ១៩៨៩, D366/7.1.660 ត្រង់ ERN 00442676។

51 គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យប្រចាំអង្គការ UNESCO, News Bulletin 17/81, ៥ តុលា ១៩៨១, *កិច្ចប្រជុំត្រីភាគីនៃគណៈកម្មាធិការពិសេស*, D56-Doc. 233 ត្រង់ ERN S 00028022; បេសកកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់ អ.ស.ប, សេចក្តីប្រកាសព័ត៌មានលេខ 069/82,, ១៥ កញ្ញា ១៩៨២, *អនុប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន កំពុងស្ថិតនៅញូវយ៉ក,* D56-Doc. 259 ត្រង់ ERN S 00031853; បេសកកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់ អ.ស.ប, សេចក្តីប្រកាសព័ត៌មានលេខ 077/82, ២៦ វិច្ឆិកា១៩៨២, *កម្ពុជាប្រជាធិបតេយ្យនៅឯកិច្ចប្រជុំរៀបចំផែនការនៅទីក្រុងកូឡុំបូ*, D56-Doc. 262 ត្រង់ ERN S 00031886-87; បេសកកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់ អ.ស.ប, សេចក្តីប្រកាសព័ត៌មានលេខ 035/85, ១០ មេសា ១៩៨៥, *គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ជួបជាមួយមេដឹកនាំគណបក្សកាន់អំណាចជប៉ុន,* D56-Doc. 311 ត្រង់ ERN S 00039016; BBC, *មន្ត្រីកម្ពុជាប្រជាធិបតេយ្យនិយាយថា ប៉ុល ពត មានសុខភាពល្អ,* ១០ មេសា ១៩៨៥, D56-Doc.310 ត្រង់ ERN 00137579 [ការរាយការណ៍ពីសេចក្តីថ្លែងការណ៍របស់ អៀង ធីរិទ្ធ ថា "ប៉ុល ពត នៅតែជាមេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងប្រឆាំងនឹងវៀតណាម នៅកម្ពុជា"]។

52 Hsinhua Agency, *មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចុះពិនិត្យសមរភូមិ*, ៥ សីហា ១៩៨១, D56-Doc. 224 ត្រង់ ERN S 00029054; លិខិតសារាចរណ៍ណែនាំរបស់កម្ពុជាប្រជាធិបតេយ្យធ្វើឡើងដោយ ខៀវ សំផន និង នួន ជា, ៣០ វិច្ឆិកា ១៩៨១, D56-Doc. 236 ត្រង់ ERN S 00020383; DK Mission to the UN Press Release 011/82, 4 February 1982, D56-Doc. 241 at ERN S 00031489 (នួន ជា ចុះពិនិត្យភាគខាងត្បូងបាត់ដំបង); បេសកកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់ អ.ស.ប, សេចក្តីប្រកាសព័ត៌មានលេខ 064/82, ១៨ សីហា ១៩៨២, D56-Doc. 256 ត្រង់ ERN S 00031835 (ខៀវ សំផន និង នួន ជា ស្ទាបស្ទង់សមរភូមិបាត់ដំបង); ត្រង់សេចក្តីថ្លែងការណ៍របស់ចលនាសម្ព័ន្ធភាពជាតិប្រជាធិបតេយ្យ, ៨ កញ្ញា ១៩៩៦, D56-Doc. 444 ត្រង់ ERN 00000959។.

53 David Chandler, *បងធំទីមួយ,* D222/1.3 ERN 00393087 (និយាយថា នៅចុងខែឧសភា ១៩៩២, ប៉ុល ពត, នួន ជា, និង តា ម៉ុក បានបដិសេធចំពោះអធិការកិច្ច អ.ស.ប ដើម្បីបានចូលតំបន់នានាដែលពួកគេត្រួតត្រា, បានបញ្ជាក់ពីភាពគ្មានឆន្ទៈដើម្បីទម្លាក់អាវុធរបស់កងទ័ពខ្លួន និងបានបដិសេធមិនព្រមចចារជាមួយ "ពួកអាយ៉ងវៀតណាម" នៅភ្នំពេញ) ។ BBC, *ប្រជាជនក្នុងស្រុកមានការភ័យខ្លាចការផ្ទុះសង្គ្រាម ជាមួយខ្មែរក្រហមនៅលើផ្លូវលេខ១០,* ២៩ ធ្នូ ១៩៩៥, D56-Doc. 422 ត្រង់ ERN 00107753; Bangkok Post, *កម្ពុជា* -

ឡើងទេ រហូតដល់ខែកញ្ញា ឆ្នាំ១៩៩៦ ទើប អៀង សារី និង អៀង ធីរិទ្ធ បានចុះចូលជាមួយរដ្ឋាភិបាល[54]។ មានឱកាសជាច្រើនក្នុងខែតុលា និងវិច្ឆិកា ឆ្នាំ១៩៩៦ ដែល នួន ជា និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដទៃទៀត បានគេចខ្លួនចូលប្រទេសថៃដើម្បីគេចពីការតាមចាប់យ៉ាងប្រផាប់ប្រភីងពីសំណាក់កងទ័ពរដ្ឋាភិបាល[55]។ ក្នុងខែមករាឆ្នាំ១៩៩៨ នួន ជា បានបដិសេធមិនព្រមផ្តល់ប៉ុល ពត ទៅឱ្យតុលាការអន្តរជាតិ ឬតុលាការយោធាឡើយដោយថ្លែងជាសាធារណៈថា គាត់ នឹងការពារ លើការប៉ុនប៉ងណាមួយដើម្បីចាប់ខ្លួនគាត់[56]។ នួន ជា និង ខៀវ សំផន នៅបន្តការតស៊ូរបស់ខ្លួន និងមិនបានចុះចូលទេរហូតដល់ខែធ្នូ ឆ្នាំ១៩៩៨[57]។

## III. អំណះអំណាង

### គោលការណ៍ទូទៅទាក់ទងនិងការព្យួរចិរវេលាអាជ្ញាយុកាល

១៩- ពាក្យឡាតាំងដែលថា *Contra non valentem agere nulla currit praeseriptio*[58] គឺជាគោលការណ៍ដែលត្រូវបានអនុវត្តជាញឹកញាប់ទាំងក្នុងទម្លាប់នៃការអនុវត្តជាតិ[59] និងអន្តរជាតិ[60]។

---

*ប៉ុល ពត ត្រូវបានគេឃើញនៅតំបន់ក្បាលរីង,* ៦ មករា ១៩៩៨, D56-Doc. 466 ត្រង់ ERN 00131101 (រាយការណ៍អំពីការវាយប្រហារដ៏ខ្លាំងក្លារវាងកងទ័ពខ្មែរក្រហម និងកងកម្លាំងរដ្ឋាភិបាល នៅច្រកឆ្លងកាត់ចុងចម Chong Chom pass)។

[54] Jiji Press English News Service, ត្រង់ *អៀង សារី ប្រកាសពីការចចារផ្លូវការជាមួយរដ្ឋាភិបាល.*, ៩ កញ្ញា ១៩៩៦, D56-Doc. 445 ត្រង់ ERN 00115846; ព្រះរាជក្រឹត្យព្រះប្រទានដោយព្រះមហាក្សត្រ នរោត្តម សីហនុ លើកលែងទោសចំពោះ អៀង សារី, ១៤ កញ្ញា ១៩៩៦, D366/7.1.191 ត្រង់ ERN 00523598។

[55] AFP, *ពួកមេដឹកនាំក្បាលរីងខ្មែរក្រហមគេជឿថា នៅក្នុងប្រទេសថៃ,* ២ តុលា ១៩៩៦, D56-Doc. 449ត្រង់ ERN00107559; Associated Press, *ពួកក្បាលរីងខ្មែរក្រហមបដិសេធអំណោះស្រាយនិរទេស,* ១៤ វិច្ឆិកា ១៩៩៦, D56 ត្រង់ ERN001079161។

[56] Bangkok Post, *កម្ពុជា - ប៉ុល ពត ត្រូវបានគេឃើញនៅតំបន់ក្បាលរីង,* ៦ មករា ១៩៩៨, D56-Doc. 466 ត្រង់ ERN 00131101; Dow Jones Newswire, *យើងត្រូវតែមានសីលធម៌–អ្នកចាប់ចង,* ៦ មករា ១៩៩៨, D56-Doc. 467 ត្រង់ ERN 00108206 [រាយការណ៍នូវសេចក្តីថ្លែងការណ៍ធ្វើឡើងដោយ នួន ជា ថា ប៉ុល ពត នឹងមិនត្រូវផ្តល់ទៅឱ្យរដ្ឋាភិបាល ឬសហគមអន្តរជាតិដើម្បីការវិនិច្ឆ័យទោសឡើយ"]; *គ្មានការរត់គេចខ្លួនបានឡើយសម្រាប់បុរសមានជម្ងឺ ប៉ុល ពត ដែលស្ថិតក្រោមការចាប់ខ្លួនដាក់ឱ្យនៅតែក្នុងផ្ទះនៅក្នុងព្រៃ,* ៧ មករា ១៩៩៨, D56-Doc. 468 ត្រង់ ERN 00108207; New York Times, *នៅលើជើងចុងក្រោយបង្អស់របស់ខ្លួន, កងទ័ពកម្ពុជាដ៏ស្រវេះស្រវោចបំផុត,* ២០ តុលា ១៩៩៧, D56-Doc. 463 ត្រង់ ERN 001081681។

[57] សេចក្តីថ្លែងការណ៍ដោយ នួន ជា ជូនសម្តេច ហ៊ុន សែន, ២៥ ធ្នូ ១៩៩៨, ERN 00531218; Alexander Hinton, *ហេតុបានជាពួកគេសម្លាប់?* D313/1.2.7 ត្រង់ ERN 00431457; Nic Dunlop, *ពេជ្ឈឃាដបាត់ខ្លួន,* D222/1.4 ត្រង់ ERN 00370203; David Chandler, *សម្លេងពីមន្ទីរស-២១,* D108/50/1.4.6 ត្រង់ ERN 00192858; AP, *ពួកមេដឹកនាំកំពូលខ្មែរក្រហមនឹងចុះចូល,* ២៥ ធ្នូ ១៩៩៨, D56-Doc. 477 ត្រង់ ERN 00132427; AFP, *ពួកមេដឹកនាំកំពូលខ្មែរក្រហមនឹងចុះចូលជាមួយរដ្ឋាភិបាល,* ២៦ ធ្នូ ១៩៩៨, D56-Doc. 478 ត្រង់ ERN 00132425.

[58] "អាជ្ញាយុកាលមិនប្រើប្រឆាំងនឹងជនដែលមិនអាចប្រព្រឹត្តទេ" ។

វាជាគោលការណ៍ច្បាប់ធម្មជាតិ[61] ដែលបានដាក់បញ្ចូលក្នុងករណីយុត្តិសាស្ត្រ និងច្បាប់លក្ខន្តិកៈនានារបស់ប្រទេសបារាំង និងនៅក្នុងប្រព័ន្ធដែលយកតាមច្បាប់ស៊ីវិលបារាំង នៅក្នុងគោលការណ៍ *empêchement d'agir* ("អសមត្ថភាពនៃសកម្មភាព")[62]។

២០- ជាងនេះទៅទៀត ដូចបានកត់សម្គាល់ដោយអង្គបុរេជំនុំជម្រះ គោលការណ៍ជាមូលដ្ឋាននៃច្បាប់លក្ខន្តិកៈស្តីពីអាជ្ញាយុកាល "សន្មតជាមុនថា ស្ថាប័នតុលាការប្រតិបត្តិយ៉ាងមានប្រសិទ្ធិភាព ដើម្បីឱ្យកិច្ចដំណើរការនីតិវិធីចាប់ផ្តើមចាក់ឫស"[63]។ ប្រព័ន្ធតុលាការដែលអាចបំពេញមុខងារបាន គឺជាលំហូរនៃថិរវេលាអាជ្ញាយុកាល[64]។

២១- គោលការណ៍ទាំងនេះអាចអនុវត្តបានដើម្បីកំណត់ថាតើ ថិរវេលានៃអាជ្ញាយុកាលដែលមានរយៈពេលដប់ឆ្នាំមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ រាំងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មជាតិដែរឬទេ។ នៅក្នុងយុត្តិសាស្ត្ររបស់បារាំងដែលគេអាចទាញយកបាន ពាក្យថា *Contra non valentem* អាចត្រូវបានអនុវត្តប្រសិនបើពុំមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ ដរាប

---

[59] **United States**: *Sandvik ទល់នឹង ស.រ.អា*, 177 F.3d 1269, 1271 (11th Cir.1995) "ការព្យួរថិរវេលាអាជ្ញាយុកាលសមធម៌ គឺជាការសមស្រប ប្រសិនបើអ្នកប្តឹងមិនបានដាក់បណ្តឹងទាន់ពេលដោយសារតែកាលៈទេសពិសេសដែលហួសពីការត្រួតត្រារបស់ខ្លួន និងដែលមិនអាចជៀសផុត ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក្តី");. **Canada**: ក្រមរដ្ឋប្បវេណីរបស់កេបិច, មាត្រា២៩០៤ ។ **France**:, ក្រមរដ្ឋប្បវេណី មាត្រា២២៣៤,ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៦ (ដាច់ខាត ឬមិនអាជំនះបាន, ធ្វើឱ្យកិច្ចដំណើរការនីតិវិធីមិនអាចធ្វើទៅបាន)។ **Germany**: ក្រមរដ្ឋប្បវេណីរបស់អាល្លឺម៉ង, ជំពូក ២០៦ ("ត្រូវបានរាំងដោយករណីប្រធានស័ក្តពីការចោទប្រកាន់លើសិទ្ធិរបស់គាត់") ។ **Spain**: *Morgan ទល់នឹង Robinson*, 12 Mart. (O. S.) 77, 13 Am. Dec. 366 (ច្បាប់អេស្ប៉ាញ) ។ **Hong Kong**: ជំពូក 347: បទប្បញ្ញត្តិអាជ្ញាយុកាល ឆ្នាំ១៩៩៧ (HK), §30។ **Botswana:** ជំពូក១៣:០១ (អាជ្ញាយុកាល) §§ 8 (1) (C), 11។ **New Zealand:** បទប្បញ្ញត្តិអាជ្ញាយុកាល 2010 §§ 45, 46។

[60] មាត្រា១០.៨ នៃគោលការណ៍ UNIDROIT 2004; អនុសញ្ញា អ.ស.ប ស្តីពីអាជ្ញាយុកាល, មាត្រា១៥; ច្បាប់គំរូស្តីពីការផ្សះផ្សាខាងពាណិជ្ជកម្មអន្តរជាតិរបស់ UNCITRAL ឆ្នាំ២០០២, មាត្រា X ("ការព្យួរថិរវេលាអាជ្ញាយុកាល") ។

[61] *សូមអាន Morgan ទល់នឹង Robinson*, 12 Mart. (O. S.) 77, 13 Am. Dec. 366 ។

[62] Cass.crim. 28 mars 2000 (Gaz.Pal. 2000 II Chr.crim. 2160); Cass.crim. 1er août 1919 (Gaz.Pal. 1919 II 176, Dames G...d); ក្រមនីតិវិធីព្រហ្មទណ្ឌរបស់កាំម៉ែរូន, មាត្រា៦៨; ក្រមរដ្ឋប្បវេណីរបស់កេបិច, មាត្រា២៩០៤; *គណៈកម្មាធិការសេវាកម្មសាធារណៈទល់នឹង Maynard* (1996) JLR 343 at 352; *Robertson ទល់នឹង ក្រុមហ៊ុន Lazard Trustee Co Ltd* (1994) JLR 103 ត្រង់ 112 [Jersey និង Guernsey]។

[63] *សូមអាន* សាលដីការបស់ អបជ លើករណីរបស់ អៀង សារី, កថាខ័ណ្ឌទី២៨៥ និងប្រភពច្បាប់នានាដែលបានលើកយោងនៅក្នុងកំណត់សំគាល់ចុងទំព័រលេខ៥២១ និង៥២២ ។

[64] សេចក្តីសម្រេចរបស់ អជសដ ស្តីពីអាជ្ញាយុកាល, កថាខ័ណ្ឌទី១៧ និងប្រភពច្បាប់នានាដែលបានលើកយោងនៅក្នុងកំណត់សំគាល់ចុងទំព័រលេខ២៥ ។

ណាគេបាន "អនុវត្តដោយប្រុងប្រយ័ត្ន និងតែនៅពេលណាដែលស្មារតី និងចេតនាជាក់ស្តែងនៃច្បាប់ច្បាស់លាស់ មិនត្រូវបានរំលោភបំពាន"[65]។ នៅក្នុងករណីនេះ ទាំងចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់រួចហើយដែរថា ចិរវេលានៃអាជ្ញាយុកាលអាចព្យួរបានអនុលោមតាមគោលការណ៍ខាងលើ តាមការសម្រេចជាឯកច្ឆ័ន្ទថា ចិរវេលាត្រូវបានព្យួរនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ដោយសារគេគ្មានប្រព័ន្ធច្បាប់ដែលអាចបំពេញមុខងារបាន ឬប្រព័ន្ធតុលាការនៅកម្ពុជា និងថាបើដូច្នេះ ការចោទប្រកាន់ក៏មិនអាចកើតឡើង[66]។ ដូចបានកំណត់ខាងក្រោមគោលការណ៍ដូចគ្នានេះគួរតែបានអនុវត្តដើម្បីព្យួរចិរវេលានៃអាជ្ញាយុកាលពីឆ្នាំ១៩៧៥ យ៉ាងហោចណាស់ដល់ឆ្នាំ១៩៩១ ដោយហេតុថាចិរវេលានៃអាជ្ញាយុកាលដប់ឆ្នាំនេះ មិនបានចាប់ផ្តើមទេរហូតដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ឬ ក្រោយមកទៀត។

### ខ. ការព្យួររយៈពេលអាជ្ញាយុកាល ដោយមកពីគ្មានប្រព័ន្ធច្បាប់ដែលដំណើរការបាន

២២- ទាំងអង្គបុរេជំនុំជម្រះ និងទាំងអង្គជំនុំជម្រះសាលាដំបូង សុទ្ធតែបានសម្រេចសេចក្តីថា ត្រូវព្យួរអាជ្ញាយុកាលក្នុងអំឡុងពេលដែលតុលាការមិនដំណើរការ និងមិនអាចមានលទ្ធភាពបើកសវនាការលើសំណុំរឿងណាមួយបាន[67]។

២៣- គេត្រូវតែព្យួររយៈពេលអាជ្ញាយុកាល ក្នុងអំឡុងពេលដែលតុលាការបិទ ដោយហេតុថាការណ៍នេះបង្កើតបានជាអលទ្ធភាពនៃសកម្មភាព[68]។ នៅក្នុងស្ថានភាពនេះ រយៈពេលអាជ្ញាយុកាលចាប់

---

[65] *Hatch ទល់នឹង Gilmore*, 3 La. Ann. 508 ។

[66] សេចក្តីសម្រេចរបស់ អជសដ ស្តីពីអាជ្ញាយុកាល, កថាខ័ណ្ឌទី១៤ ។

[67] សាលដីការបស់ អបជ លើករណីរបស់ អៀង សារី, កថាខណ្ឌទី ២៨៥ ។ សេចក្តីសម្រេចរបស់ អជសដ ស្តីពីអាជ្ញាយុកាល, កថាខណ្ឌទី ១៤, ១៦-១៧, ២៩ (កំណត់សម្គាល់ជើងទំព័រលេខ ៤៨) ។

[68] ករណីរបស់ *Hangar ទល់នឹង Abbott,* ៧៣ ស.រ.អា. ៥៣២ (ឆ្នាំ១៨៦៧) (ដោយបានសម្រេចថាអាជ្ញាយុកាលនៅក្នុងបណ្តឹងទាមទារសំណងរដ្ឋប្បវេណីមិនមានលំហូរទេ ខណៈដែលតុលាការនៅរដ្ឋ Arkansas ត្រូវបានបិទដោយសារសង្គ្រាមស៊ីវិល)។ ករណីរបស់ *Brown ទល់នឹង Hiatts,* ៨២ ស.រ.អា. ១៧៧ (ឆ្នាំ១៨៧២) ("អាជ្ញាយុកាល, ដោយមានការកំណត់រយៈពេលមួយដែលនៅក្នុងរយៈពេលនោះគេបានអះអាងនូវសិទ្ធិក្នុងការធ្វើសកម្មភាព, ដំណើរការទៅនៅលើគោលការណ៍ដែលថា តុលាការនៃប្រទេសដែលជនត្រូវបានចោទប្រកាន់រស់នៅ ឬមានទ្រព្យសម្បត្តិដែលគេត្រូវរឹបអូស គឺនៅបើកចំហរចំពោះដើមបណ្តឹងរដ្ឋវេណីក្នុងរយៈពេលនៃអាជ្ញាយុកាលនោះ")។ សូមមើលផងដែរ, ក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់, វាក្យខណ្ឌទី ២០៣(ចាស់)៖ "អាជ្ញាយុកាលត្រូវបានព្យួរ ដរាបណាការបង្គាប់ត្រូវបានរារាំងមិនឲ្យអនុវត្តសិទ្ធិរបស់ខ្លួនបើការគ្រប់គ្រងលើវិស័យយុត្តិធម៌បានឈប់ដំណើរការ"។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសស្វ៊ីស, វាក្យខណ្ឌទី

00700690



ផ្ដើម ជាថ្មីឡើងវិញតែកាលណាតុលាការនានាអាចត្រូវ “រកបានយ៉ាងមានប្រសិទ្ធភាព” ប៉ុណ្ណោះ[69]។ បន្ថែមលើនេះ ដើម្បីឱ្យតុលាការមួយអាចបើកបាន នោះប្រព័ន្ធច្បាប់ត្រូវតែមានលទ្ធភាពអាចធ្វើសវនាការយ៉ាងមានប្រសិទ្ធភាពលើសំណុំរឿងនោះ មានន័យថា *នៅក្នុងចំណោមបញ្ហាទាំងនោះ* វាត្រូវតែមានលទ្ធភាពប្រមូលភស្តុតាង, ស្ដាប់ចម្លើយសាក្សីដោយមិនមានការភ័យខ្លាចពីការសងសឹក, ស្វែងយល់ពីអង្គហេតុទាំងអស់, និងមិនមានការជ្រៀតជ្រែកអ្វីទាំងអស់[70]។ ដោយហេតុនេះ សូម្បីតែនៅក្នុងប្រទេសនានាដែលប្រព័ន្ធច្បាប់នៅកំពុងតែដំណើរការ តែកាលណាមានវត្តមាននៃកត្តាផ្សេងៗដែលមកបង្អាក់ដល់“ការគ្រប់គ្រងដ៏ត្រឹមត្រូវលើវិស័យយុត្តិធម៌” លំហូរ នៃអាជ្ញាយុកាលគឺត្រូវបានព្យួរហើយ[71]។ ដោយឡែក ការណ៍នេះគឺមាននៅពេលដែលជនចាប់ចោទត្រូវទទួលខុសត្រូវតាមរបៀបណាមួយ ចំពោះភាពលំបាកនានាក្នុងការគ្រប់គ្រងលើវិស័យយុត្តិធម៌[72]។

២៤- តុលាការសិទ្ធិមនុស្សអឺរ៉ុបធ្លាប់បានឱ្យនិយមន័យពីពាក្យ “តុលាការ” ថាជាអង្គភាពមួយដែលអនុវត្តនូវមុខងារយុត្តិធម៌ “ដោយមានមូលដ្ឋាននៅលើវិធាននៃច្បាប់” និងធានាពីសិទ្ធិនានាតាមផ្លូវច្បាប់ ជាមូលដ្ឋាន[73]។ សមត្ថភាពក្នុងការរៀបចំការការពារក្ដី ការប្រមូលភស្តុតាង និង ការស្ដាប់ចម្លើយ និង

---

១៩៩៦ ៖ “អវត្តមាននៅក្នុងការបំពេញសេវាយោធា ឬស៊ីវិល, ឬការឈប់ទាំងស្រុងនៃការគ្រប់គ្រងលើវិស័យយុត្តិធម៌នៅពេលមានសង្គ្រាម ឬពេលមានរោគប៉េស្ត, បានបញ្ឈប់មិនត្រឹមតែនៅពេលចាប់ផ្ដើមប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងនៅពេលកំពុងមានលំហូរនៃអាជ្ញាយុកាលក្នុងរយៈពេលនៃការរារាំងនោះ ទៀតផង។

[69] ករណីរបស់ *Forti ទល់នឹង Suarez-Mason*, 672 F.Supp 1531, 1550 (1987) (ដោយបានព្យួរអាជ្ញាយុកាលចំពោះការទាមទារប្រឆាំងនឹងនាយទាហានយោធាអាហ្សង់ទីនម្នាក់ រហូតដល់ពេលបែបដូច្នោះដោយហេតុថាមានរដ្ឋាភិបាលដែលត្រូវបានបោះឆ្នោតជ្រើសរើសតាមបែបប្រជាធិបតេយ្យ)។

[70] ករណីរបស់ *Arce ទល់នឹង Garcia*, 434 F.3d 1254 (11th Cir. 2006)។ ករណី *Hilao ទល់នឹង Estate of Marcos*, 103 F.3d 767, 773 (9th Cir.1996)។ ករណីរបស់ *Cabello ទល់នឹង Fernandez-Larios*, 402 F.3d 1148, 1153 (11th Cir. 2005)។

[71] នៅក្នុងករណីរបស់ *Arce ទល់នឹង Garcia*, 434 F.3d 1254, ទាំងដើមបណ្ដឹង និងទាំងចុងចោទ រស់នៅក្នុងសហរដ្ឋ។ យ៉ាងណាក៏ដោយ តុលាការបានព្យួររយៈពេលអាជ្ញាយុកាលនៅក្រោម *ច្បាប់ស្ដីពីការការពារជនរងគ្រោះពីអំពើទារុណកម្ម* ក្នុងអំឡុងពេលដែលស្ថានភាពក្នុងប្រទេសកំណើតរបស់ខ្លួននៅអែលសាវ៉ាឌ័រ មិនអនុញ្ញាតឱ្យមានការប្រមូលនូវព័ត៌មានឱ្យបានត្រឹមត្រូវ។ នៅក្នុងករណីរបស់ *Cabello ទល់នឹង Fernandez-Larios*, 402 F.3d 1148, តុលាការបានព្យួររយៈពេលអាជ្ញាយុកាល ពីព្រោះស្ថានភាពនយោបាយនៅក្នុងប្រទេសឈីលី បានធ្វើឱ្យមានការពិបាកចំពោះជនរងគ្រោះក្នុងការស៊ើបអង្កេតលើឧក្រិដ្ឋកម្មនានា (ត្រង់ 1153)។

[72] សូមមើលផ្នែក **៣.ឃ** ខាងក្រោមពាក់ព័ន្ធនឹងកំហុស ឬការបន្លំបោកប្រាស់ (fault or fraud) របស់ចុងចោទ។

[73] ករណីរបស់ *Belilos ទល់នឹង Switzerland*, ពាក្យស្នើសុំលេខ ១០៣២៨/៨៣, ECtHR, ថ្ងៃទី២៩ មេសា ១៩៨៨, កថាខណ្ឌទី ៦៤។ ករណីរបស់ *Le Compte, Van Leuven និង De Meyere ទល់នឹង Belgium*, ពាក្យស្នើសុំលេខ ៦៨៧៨/៧៥, ៧២៣៨/៧៥, ECtHR, ថ្ងៃទី២៣ មិថុនា ១៩៨១, កថាខណ្ឌទី ៥៥។

ស្ហរដេញដោលសាក្សី គឺជាសមាសធាតុយ៉ាងសំខាន់នៃការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ[74]។ ជនជាប់ចោទ ត្រូវតែមានសិទ្ធិ និងធនធានដែលមានស្រាប់ដើម្បីបង្កើតឱ្យបាននូវការការពារមួយដ៏គ្រប់គ្រាន់ ដោយរួមទាំងការដែលអាចរកបាននូវមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួនថែមទៀតផង[75]។ បើមិនបានត្រូវទៅតាមលក្ខខណ្ឌតម្រូវអប្បបរមាបែបដូច្នេះទេ គេមិនអាចពិចារណាលើអង្គភាពមួយថាជា តុលាការមួយដែលដំណើរការបានដោយមានលទ្ធភាពធ្វើការកាត់សេចក្តីលើបញ្ហាអ្វីមួយបាននោះទេ ហើយនឹងមានអលទ្ធភាពទាំងស្រុងក្នុងការនាំយកនូវករណី ដែលមានអត្ថិភាពមួយដែលអនុញ្ញាតឱ្យមានការព្យួរអាជ្ញាយុកាល។

២៥- ក្នុងករណីនេះ ដូចបានវែកញែកបង្ហាញខាងលើនៅក្នុងផ្នែក II.ក រួចមកហើយ គឺមិនមានតុលាការណាដែលដំណើរការទេនៅក្នុងប្រទេសកម្ពុជានៅក្នុងអម្លុងពេលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ ដែលអាចឱ្យមានលទ្ធភាពធ្វើការកាត់សេចក្តីលើជនជាប់ចោទ ឱ្យបានស្របទៅតាមគោលការណ៍យុត្តិធម៌ និងវិធានច្បាប់នោះឡើយ[76]។ នៅក្នុងអម្លុងពេលនោះ ប្រទេសនេះគ្មានតុលាការណាមួយដែលមានមន្ត្រីតុលាការដែលមានគុណវុឌ្ឍិ ដែលធ្វើឱ្យមានដំណើរការអនុលោមទៅតាមនីតិវិធីដ៏ល្អិតល្អន់ និងច្បាប់ដែលចែងពីសិទ្ធិ កាតព្វកិច្ច និងអំណាច (របស់ភាគីនានា) ដើម្បីឱ្យបង្កើតបានទៅជានីតិវិធីស្របតាមច្បាប់សម្រាប់កាត់សេចក្តីជនជាប់ចោទពីបទមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនាឡើយ។ ដើម្បីឱ្យជាក់លាក់ មានតែតុលាការទាំងប៉ុន្មាន ដែលមានស្រាប់នៅក្នុងអម្លុងពេលនោះទេ ដែលត្រូវបានប្រើប្រាស់ជាសំខាន់ដើម្បីធ្វើការជំនុំជម្រះក្តីលើបទល្មើសនានាទាក់ទងនឹងនយោបាយតែប៉ុណ្ណោះ ដូចជា "ក្បត់នឹងបដិវត្តន៍"ជាដើម។ អតីតកម្មាភិបាលខ្មែរក្រហមដែលត្រូវចាប់បានទាំងនោះ គឺមិនត្រូវបានគេបញ្ជូនទៅជំនុំជម្រះនៅឯតុលាការឡើយ។ មិនមាន

[74] អនុសញ្ញាទីក្រុងហ្សឺណែវទី III, មាត្រា ៩៦.៤។ ICCPR, មាត្រា ១៤.៣.ខ និង ១៤.៣.ង (ពេលវេលា និងឧបករណ៍គ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី)។ អនុសញ្ញាអាមេរិកាំង, មាត្រា ៨.២.គ។ អនុសញ្ញាអឺរ៉ុប, មាត្រា ៦.៣.ខ។ លក្ខន្តិកៈតុលាការ ICTY, មាត្រា ២១.៤.ខ។ លក្ខន្តិកៈតុលាការ ICC, មាត្រា ៦៧.១.ឃ។

[75] ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងទាក់ទងទៅនិងការការពារជនរងគ្រោះក្នុងជម្លោះប្រដាប់អាវុធដែលមិនមែនជាលក្ខណៈអន្តរជាតិ(ពិធីសារII) ថ្ងៃទី៨ ខែមិថុនា ១៩៧៧, ១១២៥.U.N.T.3609, មាត្រា៦(២)(ក)ធម្មនុញ្ញIMT (Nuremberg), មាត្រា16(ឃ); ICCPR, article 14(3)(ឃ)។

[76] តាមគោលបំណងនៃការលើកឡើងនូវទស្សករណ៍នេះ គឺសហព្រះរាជអាជ្ញា ចង់ផ្តោតទៅលើថា តើមានអង្គហេតុផ្សេងៗដែលអនុញ្ញាតឱ្យព្យួររយៈពេលនៃអាជ្ញាយុកាលរហូតដល់ថ្ងៃទី២៣ តុលា ១៩៩១ ដែរឬទេ? (ពេលដែលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) ពីព្រោះអាជ្ញាយុកាលនេះមិនត្រូវបានគេចាប់ផ្តើមគិតទេរហូតមកទល់ពេលនោះ ការពន្យារពេលនៅខែសីហា ឆ្នាំ២០០១ នៃអាជ្ញាយុកាលដែលនៅក្នុងមាត្រា៣នៃច្បាប់ អវតក គឺបានកើតឡើងនៅមុនពេលត្រូវផុតកំណត់នៃអាជ្ញាយុកាល ដែលហេតុដូចនេះ គឺមិនអាចរំលោភទៅលើគោលការណ៍ស្តីពីនីត្យានុកូលភាពបានឡើយ។

មេធាវីដែលមានការបណ្ដុះបណ្ដាលជាអាជីពដែលអាចធ្វើជាតំណាងឱ្យជនជាប់ចោទ ប្រកបដោយសមត្ថភាពឡើយ។ ការជំនុំជម្រះក្ដីនៅចំពោះមុខតុលាការមួយដែលមិនលំអៀង, គោលការណ៍ស្ដីពីសច្ចធារណ៍នីរទោស[77] និងការការពារក្ដីដោយត្រឹមត្រូវ និងវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលសវនាការទាំងអស់នេះ គឺសុទ្ធតែមិនអាចមានលទ្ធភាពធ្វើទៅបានទាំងអស់ព្រោះដោយសារសង្គ្រាមស៊ីវិលដែលកំពុងតែបន្តកើតមានរវាងខ្មែរក្រហមហើយនឹងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ គ្មានសាលាឧទ្ធរណ៍ និងមិនមានសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍សម្រាប់ ជនដែលជាទណ្ឌិតនោះឡើយ។

២៦- ដំណើរការក្នុងការបង្កើតឡើងនូវប្រព័ន្ធច្បាប់និងតុលាការនៅក្នុងប្រទេសកម្ពុជាដើម្បីឱ្យបានត្រឹមត្រូវតាមច្បាប់ គឺមិនទាន់បានចាប់ផ្ដើមទេរហូតទាល់តែបន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ ដែលមានការអនុម័តនូវច្បាប់ UNTAC នាខែកញ្ញា ឆ្នាំ១៩៩២ និងច្បាប់ស្ដីពីការការជំនុំជម្រះក្ដីលើបទល្មើសព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញ ខែកញ្ញា ឆ្នាំ១៩៩៣។ ហេតុនេះ ដោយសារគ្មានតុលាការដែលដំណើរការ ដែលអាចឱ្យជនជាប់ចោទត្រូវបានធ្វើការជំនុំជម្រះក្ដីនៅក្នុងប្រទេសកម្ពុជា នៅមុនរយៈពេលនោះ អង្គជំនុំជម្រះសាលាដំបូងគួរធ្វើសេចក្ដីសន្និដ្ឋានថា អាជ្ញាយុកាលត្រូវបានព្យួរ យ៉ាងហោចណាស់ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែតុលា ឆ្នាំ១៩៩១។

## គ. រយៈពេលនៃការព្យួរអាជ្ញាយុកាលនៅក្នុងអម្លុងពេលសង្គ្រាម

២៧- មានការបង្ហាញភស្តុតាងយ៉ាងច្បាស់នៅក្នុងទម្លាប់អនុវត្តន៍របស់ជាតិ និងអន្តរជាតិថា ស្ថានភាពកំពុងមានសង្គ្រាមមួយដែលបានធ្វើឱ្យដំណើរការរបស់តុលាការត្រូវផ្អាក ទោះបីជាផ្ទៃក្នុង ឬមកពីខាងក្រៅក៏ដោយ ចាំបាច់គឺត្រូវតែព្យួរអាជ្ញាយុកាល[78]។ នៅពេលក្រោយសង្គ្រាមនៅប្រទេសអាល្លឺ

---

[77] ការនិយាយអាក្រក់ជាសាធារ អំពី "បនប៉ុល ពត អៀងសារី"ដោយសាធារណៈរដ្ឋប្រជាមានិតុកម្ពុជា ធ្វើឱ្យមានការសន្មត់ថាគ្មានទោស (គោលការណ៍សច្ចធារណ៍នីរទោស)ណាមួយ មិនអាចធ្វើទៅបានឡើយ ជាពិសេសនោះ គឺព្រោះដោយសារក្រិត្យដែលបង្កើតតុលាការប្រជាជនបដិវត្តន៍នោះបានប្រកាសយ៉ាងច្បាស់អំពីពិរុទ្ធភាពរបស់ពួកគេ។ *សូមអាន* ក្រិត្យច្បាប់លេខ ១, ឯកសារលេខ D288/6.9/9.3, ត្រង់លេខ ERN 00336567 (" ដោយពិនិត្យឃើញថាបន ប៉ុល ពត និងអៀង សារីបានសម្លាប់រង្គាលនូវប្រជាជនស្លូតត្រង់អស់រាប់លាននាក់ បានបង្ខំឱ្យប្រជាជនកម្ពុជាទាំងមូលត្រូវរស់នៅក្នុងសភាពនៃអំពើប្រល័យពូជសាសន៍ ទាំងខាងផ្លូវកាយនិងផ្លូវចិត្ត។ បានបំផ្លិចបំផ្លាញទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធខាងវិស័យសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ច ដែលហេតុដូចនេះ នាំមកដល់ពួកគេនូវសភាពគ្រោះថ្នាក់ដោយសារការសម្លាប់បំផុតពូជ")។

[78] *សង្គ្រាម ដែលធ្វើឱ្យការគិតអាជ្ញាយុកាលត្រូវបានព្យួរ ដោយគ្មានបទបញ្ញត្តនៃលក្ខន្តិកៈណាដែលចែងជាក់លាក់អំពីរឿងនេះ,* 137 A.L.R. 1454 (West 2011)។ ច្បាប់ឆ្នាំ១៩៤៥ (ប្រទេសអង់គ្លេស) ស្ដីពីអាជ្ញាយុកាល (ខ្មាំងនិងពួកអ្នកទោសល្មើយសឹក) §1។ Ch 15 Cypriot

00700693



ម៉ង់ មានការសម្រេចដោយក្រុមប្រឹក្សាត្រួតពិនិត្យថា នៅក្នុងសវនាការជំនុំជម្រះក្តី ឬការចោទប្រកាន់ណាមួយ "ជនជាប់ចោទមិនត្រូវមានសិទ្ធិ ក្នុងការទទួលបាននូវអត្ថប្រយោជន៍ពីអាជ្ញាយុកាលណាមួយនោះទេ" ទាក់ទងនឹងអម្លុងពេលចាប់តាំងពីថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៣៣ ដល់ ថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៤៥[79]។ នៅសហរដ្ឋអាមេរិក តុលាការនានាបានធ្វើការព្យួរអាជ្ញាយុកាលដោយភាពស៊ីសង្វាក់គ្នានៅក្នុងអម្លុងពេលដែលមានសង្គ្រាម ដោយមិនគិតអំពីថាតើការព្យួរបែបនេះតើមានចែង ឬមិនមានចែងនៅក្នុងលក្ខន្តិកៈនោះឡើយ[80]។ តុលាការនានានៃប្រទេសបារាំង និងតុលាការរបស់ប្រព័ន្ធច្បាប់ស៊ីវិលផ្សេងទៀតក៏គេបានព្យួរអាជ្ញាយុកាលដែរ ដោយផ្អែកលើមូលដ្ឋាននៃការមានអត្ថិភាពនៃស្ថានភាពកំពុងមានសង្គ្រាម[81]។

២៨- គោលការណ៍ដដែលនេះ ត្រូវបានគេពន្យារដែលនៅក្នុងបណ្តាប្រទេសដែលប្រកាន់របបដែលប្រើអំណាចផ្តាច់ការគាបសង្កត់ ដែលនៅក្នុងនោះសិទ្ធិក្នុងការប្តឹងផ្តល់តាមផ្លូវតុលាការអាចត្រូវបានរារាំង[82]។ ឧទាហរណ៍ដូចជា សាធារណៈរដ្ឋឆែកបន្ទាប់ពីការដួលរលំនៃរបបកុម្មុយនីស្តមក អាជ្ញា

---

Code; H. St. John-Mildmay, *ច្បាប់របស់ប្រទេសអ៊ីតាលីស្តីពីអាជ្ញាយុកាល* (ឆ្នាំ១៩១៦) 1 Int'l L. Notes 59។ *ច្បាប់ស្តីពីអាជ្ញាយុកាល* ឆ្នាំ២០១០ (ប្រទេសស្វ៊ីសហ្សេឡង់) §46(c) (ដែលបកស្រាយអំពីសង្គ្រាមថាជាឧបសគ្គរាំងមួយដែលប្រហាក់ប្រហែលគ្នានឹងការធ្វើឱ្យមានអសមត្ថភាពដែរ)។ Oppenheim ស្តីពីច្បាប់អន្តរជាតិ (ការបោះពុម្ពផ្សាយលើកទី២ , ឆ្នាំ១៩១២)។ Vol 2 ទំព័រ១៣៥។

[79] ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ស្តីពីការការផ្តន្ទាទោសចំពោះជនទាំងឡាយដែលត្រូវមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២០ធ្នូ១៩៤៥ មាត្រាII(៥)

[80] *ករណីរឿងក្តីរបស់ Hangar ទល់នឹង Abott, 73 U.S.532 (ឆ្នាំ១៨៦៧)* ។ *ក្រុមហ៊ុនប្រេងឥន្ធនៈនិងដែកនៃរដ្ឋ Colorado ទល់នឹងIndustrial Com'n*, 73 Colo. 579, 216 P. 706 (ឆ្នាំ១៩២៣)។ *ករណីរឿងក្តីរបស់ Inland Steel Co. ទល់នឹង Jelenovic*, 84 Ind. App. 373, 150 N.E. 391 (ឆ្នាំ១៩២៦)។ *ករណីរឿងក្តីរបស់ Maryland Cas. Co. ទល់នឹង. Vidigoj*, 207 Ky. 841, 270 S.W. 472 (ឆ្នាំ១៩២៦)។ *ករណីរឿងក្តីរបស់ Lipmanowich ទល់នឹង Crookston Lumber Co.*, 168 Minn. 332, 210 N.W. 47 (ឆ្នាំ១៩២៥)។ *ករណីរឿងក្តីរបស់ Peters ទល់នឹង McKay*, 195 Or. 412, 238 P.2d 225 (ឆ្នាំ១៩៥១), reh'g denied, 195 Or. 412, 246 P.2d 585 (ឆ្នាំ១៩៥២)

[81] Cass.crim. ចុះថ្ងៃទី១ សីហា ១៩១៩ (Gaz.Pal. 1919 II 176, Dames G...d) (អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាត្រូវបានព្យួរនៅពេលដែលនៅក្នុងទឹកដីដែលត្រូវកាន់កាប់ត្រូវបានពួកសត្រូវហាមឃាត់មិនឱ្យតុលាការបើកជំនុំជម្រះក្តី)។ Cass.-civ, ចុះថ្ងៃទី១៧ ធ្នូ ១៨៧២, D.78. 1. 227; Cass.-civ., ចុះថ្ងៃទី១៩ វិច្ឆិកា ១៨៧៣, D. 74. 1. 200, S. 74. 1. 430; Wahl, *សង្គ្រាមដែលត្រូវបានចាត់ទុកថាជាករណីប្រធានស័ក្ក, ទស្សនាវដ្តីស្តីពីប្រព័ន្ធច្បាប់ស៊ីវិលប្រចាំត្រីមាស*, 383-418 (ឆ្នាំ១៩១៥)។ James B. Thayer, Magdalene Schoch & Gordon Ireland, ឥទ្ធិពលនៃស្ថានភាពដែលកំពុងស្ថិតនៅក្នុងពេលមានសង្គ្រាមទៅលើអាជ្ញាយុកាល, 17 Tulane Law Review 416 at 420-22 (ឆ្នាំ១៩៤៣)។ ករណីរឿងក្តីរបស់ *Public Services Committee ទល់នឹង Maynard* (ឆ្នាំ១៩៩៦) JLR 343 at 352។ ករណីរឿងក្តីរបស់ *Robertson ទល់នឹង Lazard Trustee Co Ltd* (ឆ្នាំ១៩១៤) JLR 103 ត្រង់ទំព័រ១១២។

[82] *សូមអាន ករណីរឿងក្តីរបស់ Jean ទល់នឹង Dorelien*, US 11th Circuit, សំណុំរឿងលេខ 04-15666, ចុះថ្ងៃទី ១ ធ្នូ២០០៥ ("យើងកត់សំគាល់ឃើញថា គ្រប់តុលាការដែលបានចាត់ទុកថាបញ្ហាអំពីថាតើសង្គ្រាមស៊ីវិល និងរបបផ្តាច់ការដែលមានការគាបសង្កត់ណាមួយ បង្កើតបានទៅជា 'កាលៈទេសៈវិសាមញ្ញ' ដែលធ្វើឱ្យព្យួរអាជ្ញាយុកាលនៃ [Alien Tort Claim Act] ហើយនឹង [ច្បាប់ស្តីពីការការ

យុកាលត្រូវបានពន្យារនៅក្នុងអម្លុងពេលជាង៤០ឆ្នាំទាំងមូល[83]។ នៅក្នុងករណីរឿងក្តីរបស់ *Aree ទល់នឹង Garcia* មានបណ្តឹងមួយដែលធ្វើឡើងដោយពួកជនភៀសខ្លួនជនជាតិសាល់វ៉ាឌ័រប្រឆាំងនឹងមន្ត្រីយោធាជនជាតិសាល់វ៉ាឌ័រ តុលាការបានពន្យារអាជ្ញាយុកាលរហូតទល់សង្គ្រាមស៊ីវិលនៅប្រទេសអែលសាល់វ៉ាឌ័រត្រូវបានបញ្ចប់ នៅពេលកិច្ចព្រមព្រៀងសន្តិភាពត្រូវបានធ្វើការចរចារួច ហើយនឹងតុលាការឯករាជ្យត្រូវបានស្តារឡើងវិញ[84]។ នៅក្នុងករណីរឿងក្តីរបស់ Chavez *ទល់នឹង Caranza* បណ្តឹងដែលអាជ្ញាយុកាលត្រូវបានគេពន្យារបន្ថែមចំនួនពីរឆ្នាំទៀតពីព្រោះដោយសារអំពើហឹង្សាយ៉ាងរីករាលដាលនៅក្នុងប្រទេសអែលសាល់វ៉ាឌ័រ បានបន្តទៅទៀតបន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩២រហូតទល់ពេលមានការបោះឆ្នោតជាតិលើកទី១ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ១៩៩៤[85]។

២៩- គោលការណ៍អន្តរជាតិដែលអាជ្ញាយុកាលត្រូវបានពន្យារ ដោយហេតុថាមាន "សង្គ្រាមរវាងមហាអំណាច"[86] ចំនួនពីរនោះគឺបានអនុវត្តផងដែរនៅទីនេះ ព្រោះថាប្រទេសកម្ពុជាគឺជារដ្ឋមាន សង្គ្រាមរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា (ហើយក្រោយមកជា រដ្ឋកម្ពុជា) និងម្ខាងទៀតគឺរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ (ហើយក្រោយមកជា CGDK) ហើយម្យ៉ាងទៀតចាប់ពីខែមករា

---

ពារជនរងគ្រោះដោយការធ្វើទារុណកម្ម] ដែលបានឆ្លើយតបដោយវិជ្ជមាន"), ដោយលើកសំអាងលើការយល់ព្រមដែលនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើករណីរបស់អៀងសារី, លេខយោងជើងទំព័រលេខ ៥២២។

[83] តុលាការធម្មនុញ្ញនៃសាធារណៈរដ្ឋឆេក, សេចក្តីសម្រេចលើច្បាប់ឆ្នាំ១៩៩៣ ស្តីពីអនីត្យានុកូលភាពនៃរបបកុម្មុយនិស្ត, ចុះថ្ងៃទី២១ ធ្នូ ១៩៩៣,ឯកសារលេខ D288/6.9/7.12 ត្រង់លេខ ERN 00335995-96 [ ដែលបញ្ជាក់អំពីសុពលភាពនៃច្បាប់មួយនាឆ្នាំ១៩៩៣ ដែលចែងថា អាជ្ញាយុកាលនៃឧក្រិដ្ឋកម្មនានានៅក្នុងអតីតកាលនឹងមិនគិតរួមបញ្ចូលនូវអម្លុងពេលពីថ្ងៃទី២៥ កុម្ភៈ ឆ្នាំ១៩៤៨ ដល់ ថ្ងៃទី២៥ ធ្នូ ឆ្នាំ១៩៨៩ នោះទេ]។

[84] *ករណីរឿងក្តីរបស់ Arce ទល់នឹង Garcia*, 434 F.3d 1254, 1258 (11th Cir. 2006)។ សូមអានផងដែរ *ករណីរឿងក្តី Forti ទល់នឹង Suarez-Mason*, 672 F.Supp 1531, 1549-50 (ឆ្នាំ១៩៨៧)។ *ករណីរឿងក្តី Hilao ទល់នឹង អចលនទ្រព្យរបស់ Marcos*, 103 F.3d 767, 773 (9th Cir.1996) (ដែលពន្យារអាជ្ញាយុកាលដោយមានបណ្តឹងនានាប្រឆាំងនឹងអតីតជនផ្តាច់ការនៅប្រទេសហ្វីលីពីនឈ្មោះ Ferdinand Marcos រហូតដល់របបរបស់គាត់ត្រូវបានផ្តួលរលំ)។ *ករណីរឿងក្តីរបស់ Cabello ទល់នឹង Fernandez-Larios*, 402 F.3d 1148, 1153-54 (11th Cir. 2005) (ដែលពន្យារអាជ្ញាកាលរហូតដល់របប military *junta* របស់ប្រទេសឈីលីធ្លាក់ចេញពីអំណាច)។

[85] *ករណីរឿងក្តីរបស់ Chavez ទល់នឹង Carranza*, US 6th Circuit, សំណុំរឿងលេខ 06-6234, ចុះថ្ងៃទី ១៧ មីនា ២០០៩។

[86] *សង្គ្រាមជាការផ្អាកនូវលំហូរនៃអាជ្ញាយុកាលដោយអវត្តមាននៃបទប្បញ្ញត្តិជាសារធាតុដែលមានអានុភាពជាក់លាក់*, 137 A.L.R. 1454 ("ឥឡូវនេះ គេបានបង្កើតគោលការណ៍ច្បាប់អន្តរជាតិយ៉ាងម៉ត់ចត់មួយ ដែលអត្ថិភាពនៃស្ថានភាពសង្គ្រាមមួយរវាងប្រទេសពីរ ឬអំណាចពីរ ត្រូវបានផ្អាកនូវលំហូរនៃអាជ្ញាយុកាលយ៉ាងមានប្រសិទ្ធភាពចំពោះពលរដ្ឋនៃប្រទេស ឬអំណាចទាំងពីរ នៅពេលមានសង្គ្រាមបែបដូច្នោះ Hall, Treatise on International Law (8th ed, 1924), p. 459; Oppenheim, International Law (2nd ed. 1912), Vol 2, p. 135។

00700695



ឆ្នាំ១៩៧៩ រហូតមកទល់យ៉ាងហោចណាស់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ការណ៍ពិតដែលថា អង្គការសហប្រជាជាតិបានបន្តទទួលស្គាល់ពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និង CGDK ថាជាអ្នកតំណាងឲ្យប្រទេសកម្ពុជាក្នុងរយៈពេលនេះ គឺបានបញ្ជាក់ថាការណ៍នេះគឺជាសង្គ្រាមស៊ីវិល រវាងអំណាចពីរដែលប្រកួតប្រជែងគ្នាដើម្បីត្រួតត្រាលើប្រទេសនេះ[87]។ នីតិវិធីតុលាការណាមួយ ដែលពាក់ព័ន្ធទៅនឹងការតំណាងឲ្យកម្លាំងពីរនៅពេលមានសង្គ្រាម គឺស្ទើរតែមិនអាច និងមិនទំនងជាត្រូវបានដោះស្រាយទៅតាមរបៀបមួយដែលត្រឹមត្រូវ ឬតាមរបៀបតុលាការបានឡើយ ដូចដែលត្រូវបានបង្ហាញជាភស្តុតាងស្រាប់តាមរយៈ "ការកាត់សេចក្តី" ដែលត្រូវបានដំណើរការឡើងចំពោះ ប៉ុល ពត និង អៀង សារី ឆ្នាំ១៩៧៩។

៣០- លើសពីនេះទៀត ដូចដែលបានរៀបរាប់នៅខាងលើស្រាប់ អលទ្ធភាពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីចាប់ពួកមេដឹកនាំខ្មែរក្រហមយកមកកាត់ទោសដែលនៅពេលនោះស្ថិតក្នុងស្ថានភាមានសង្គ្រាម ព្រមទាំងអលទ្ធភាពក្នុងការបង្កើតប្រព័ន្ធច្បាប់ឬតុលាការណាមួយ ដែលអាចដំណើរការបានក្នុងអម្លុងពេលឆ្នាំ១៩៧៩-១៩៩១ បានផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការព្យួរអាជ្ញាយុកាល។

## ឃ. ការព្យួរអាជ្ញាយុកាលដោយសារកំហុស ឬការបន្លំរបស់ចុងចោទ

៣១- ដើម្បីសម្រេចព្យួរអាជ្ញាយុកាលរហូតដល់ខែកញ្ញា ឆ្នាំ១៩៩៣ អង្គបុរេជំនុំជម្រះបានកត់សំគាល់ថាជនជាប់ចោទ "មិនអាចទទួលបានផលប្រយោជន៍ពីការកន្លងផុតទៅនៃពេលវេលាទេ... ប្រសិនបើជនជាប់ចោទត្រូវបានគេអះអាងថា មានការទទួលខុសត្រូវមួយផ្នែកចំពោះអសមត្ថភាពនៃប្រព័ន្ធតុលាការលើការអនុវត្តកិច្ចស៊ើបសួរ និងការចោទប្រកាន់" ក្នុងអម្លុងពេលនោះ[88]។ ការសន្និដ្ឋាននេះ

[87] រដ្ឋសភាជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានទទួលស្គាល់ពីស្ថានភាពដែលបង្កើតជា "សង្គ្រាម ឬ កាលៈទេសៈលើកលែងផ្សេងៗ" ហើយនៅលើមូលដ្ឋាននោះ បានពន្យារអាណត្តិរបស់សភាជាតិដោយបានបន្ថែមចំនួនប្រាំឆ្នាំទៀត នៅក្នុងឆ្នាំ១៩៨៦ ។ សូមមើល *រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា,* មាត្រា ៩៧ ។

[88] សាលដីការបស់ អបជ លើករណីរបស់ អៀង សារី, កថាខ័ណ្ឌទី២៨៦ ។

មានការគាំទ្រដោយករណីយុត្តិសាស្ត្រ ទាក់ទងនិងការព្យួរអាជ្ញាយុកាល ប្រសិនបើអលទ្ធភាពនៃការអនុវត្តបានបណ្តាលមកពីកំហុស ឬការបន្ទុំរបស់ជនជាប់ចោទ[89]។

៣២- ក្នុងករណីនេះ ជនជាប់ចោទត្រូវទទួលខុសត្រូវដោយផ្ទាល់ទាំងចំពោះកង្វះខាតនៃប្រព័ន្ធតុលាការដែលអាចបំពេញមុខងារបានបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ និងទាំងសង្គ្រាមស៊ីវិលដែលរារាំងយ៉ាងមានប្រសិទ្ធិភាពដល់ការចោទប្រកាន់ពួកគេ ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។ ជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលបានអនុវត្តគោលនយោបាយបដិវត្តន៍របស់ពួកគេ បានស្វែងរកដើម្បីលុបបំបាត់ចៅក្រម មេធាវី និងអ្នកអាជីពច្បាប់ដទៃទៀត ព្រមទាំងបញ្ញាជនដែលត្រូវបានគេគិតថា ជាខ្មាំងវណ្ណៈ។ គឺជនជាប់ចោទខ្លួនឯងដែលជាអ្នករុះរើតុលាការ និងស្ថាប័នដទៃទៀតរបស់កម្ពុជានៅពេលបានឡើងកាន់កាន់អំណាចក្នុងខែមេសា ឆ្នាំ១៩៧៥។ គឺជនជាប់ចោទខ្លួនឯងជាអ្នកដឹកនាំសង្គ្រាមស៊ីវិលអស់រយៈជាង ១៥ឆ្នាំ ចេញពីតំបន់ភ្នំតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងមិនបានចុះចូលជាមួយរដ្ឋាភិបាលកម្ពុជាទេ រហូតដល់ឆ្នាំ១៩៩៦ និង១៩៩៨។

៣៣- ក្នុងកាលៈទេសៈទាំងអស់នេះ ជនជាប់ចោទមិនគួរអនុញ្ញាតឲ្យទទួលផលពីអំពើខុសឆ្គង និងឧក្រិដ្ឋកម្ម ដែលបានជ្រៀតជ្រែក និងរារាំងចំពោះការចោទប្រកាន់របស់ខ្លួនតាំងពីដំបូង។

## IV. សេចក្តីសន្និដ្ឋាន

៣៤- សម្រាប់មូលហេតុដូចមានចែងខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អញ្ញត្រកម្មរបស់ជនជាប់ចោទដែលបានផ្អែកលើអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋជាតិ គួរត្រូវបានបដិសេធចោល។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |

[89] *សូមអាន* ឧទាហរណ៍, Corsey ទល់នឹង Louisiana, 375 So. 2d 1319 (1979) Cass. 1e civ., 28 October 1991, Bull. Civ. I, No. 282 (Fr.); Saul Litvinoff, *Good Faith*, 71 Tulane Law Review 1645, 1660-61 (1997)។